# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




**Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center**

## ផ្នែកទី ១៖ ទិដ្ឋភាពទូទៅ

លោកស្រី **អៀង ធីរិទ្ធ** ហៅក្រៅថា “**ភា**” គឺជាជនជាប់ចោទម្នាក់ក្នុងចំណោមបីនាក់ផ្សេងទៀតនៃសំណុំរឿង០០២ របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ពីត្រឹមនេះតទៅនឹងហៅថា **អ.វ.ត.ក** ឬតុលាការ)។ លោកស្រីត្រូវបានចោទប្រកាន់ជាបណ្តោះអាសន្ន កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ ២០១០ ស្តីពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសន្ធិសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។ ទោះជាយ៉ាងនេះក្តី កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១ មេធាវីការពារក្តីរបស់លោកស្រី **អៀង ធីរិទ្ធ** បានដាក់ឲ្យវាយតម្លៃសាឡើងវិញអំពីសម្បទាខាងបញ្ញាស្មារតីរបស់ជនជាប់ចោទរូបនេះនៅក្នុងការចូលរួមការជំនុំជម្រះ និងបានអះអាងថា “ស្ថានភាពផ្លូវចិត្តរបស់ជនជាប់ចោទរារាំងសមត្ថភាពរបស់ក្រុមការពារក្តីក្នុងការរៀបចំការត្រៀមខ្លួនសម្រាប់សវនាការខាងមុខ”។[1] កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ បន្ទាប់ពីមានសវនាការជាច្រើនលើកច្រើនសា ក៏ដូចជាបន្ទាប់ពីបានទទួលការវាយតម្លៃពីវេជ្ជបណ្ឌិតជំនាញមួយចំនួនរួចមក លោកស្រី **អៀង ធីរិទ្ធ** ត្រូវបានរកឃើញថា មិនមានកាយសម្បទាសមស្របក្នុងការជំនុំជម្រះដោយផ្អែកលើមូលដ្ឋាននៃស្ថានភាពផ្លូវចិត្តរបស់គាត់។[2] អង្គជំនុំជម្រះសាលាដំបូង បានបំបែកសំណុំរឿងរបស់លោកស្រី **អៀង ធីរិទ្ធ** ចេញពីសំណុំរឿង០០២ ដើម្បីចៀសវាងការពន្យារពេលសវនាការរបស់ជនជាប់ចោទផ្សេងៗទៀត និងបានបង្គាប់ឲ្យដោះលែងលោកស្រីភ្លាមៗ និងដោយគ្មាន

---

[1] Ieng Thirith Defense. “Defense Request for Appointment of a Neuropsychiatrist to Assess Madame IENG Thirith’s Fitness to Stand Trial” (21 February 2011). E52 [hereinafter, **REQUEST FOR NEUROPSYCHIATRIST**]. par. 36.

[2] Trial Chamber. “Decision on Ieng Thirith’s Fitness to Stand Trial” (17 November 2011). E138 [hereinafter, **TRIAL CHAMBER DECISION**]. pp. 29-30.

លក្ខខណ្ឌអ្វីទាំងអស់។[3] ការិយាល័យនៃភាគីសហព្រះរាជអាជ្ញា (OCP) បានដាក់នូវបណ្តឹងសាទុក្ខភ្លាមៗដែរ[4] និងត្រូវបានទទួលយកដោយតុលាការកំពូលកាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១។[5] តុលាការកំពូលបានចេញបញ្ជាឲ្យលោកស្រី **អៀង ធីរិទ្ធ** ទទួលបាននូវការសម្រាក និងព្យាបាលទាក់ទងនឹងបញ្ហានៃការប្រើប្រាស់ថ្នាំ និងថែមទាំងបានធ្វើការវាយតម្លៃសាឡើងវិញក្នុងរយៈពេល៦ខែផងដែរ ដើម្បីរកមើលថាតើលោកស្រីអាចមានកាយសម្បទាសមស្របក្នុងការជំនុំជម្រះ ឬអត់។

ការវាយតម្លៃឡើងវិញ និងការធ្វើសវនាការពាក់ព័ន្ធជាបន្តបន្ទាប់ត្រូវបានធ្វើឡើងនៅរវាងថ្ងៃទី២៧ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១២ រួមជាមួយនឹងសេចក្តីសម្រេចចុងក្រោយពីតុលាការកាលពីថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការអនុគ្រោះដោយមិនកំណត់រយៈពេលនូវដំណើរការនីតិវិធី និងដោះលែងជាបណ្តោះអាសន្នដល់ជនជាប់ចោទរូបនេះ។ កាលពីថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ ក្រុមសហព្រះរាជអាជ្ញាភ្លាមៗនោះ បានដាក់ប្តឹងសាទុក្ខចំពោះសេចក្តីសម្រេចនេះ ផ្អែកលើមូលដ្ឋានថា ពួកគេជឿជាក់ថាតុលាការគួរតែរក្សាការឃុំខ្លួនលោកស្រី **អៀង ធីរិទ្ធ** បន្តទៅទៀត។ តុលាការកំពូលនឹងស្តាប់ការជជែកដេញដោលពីភាគីទាក់ទងលើបណ្តឹងសាទុក្ខនេះ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ ២០១២។

សំណុំរឿងរបស់ជនជាប់ចោទ **អៀង ធីរិទ្ធ** ជាថ្មីម្តងទៀតជាសវនាការនាំមុខរបស់ **អ.វ.ត.ក** ក្នុងខែនេះ រីឯគម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិនៅអាស៊ី (AIJI) កំពុងតែចុះផ្សាយនូវរបាយការណ៍ពិសេសនេះ ដើម្បីផ្តល់នូវសេចក្តីសង្ខេបសាឡើងវិញនូវបញ្ហាផ្លូវច្បាប់ដែលជាប់ជំពាក់ទាក់ទងគ្នាបូករួមនឹងបញ្ហាផ្អែកនីតិវិធីមួយចំនួនដែលបានកើតឡើងចំពោះមុខអង្គជំនុំជម្រះ ព្រមទាំងចំណាត់ការនានាកន្លងមករបស់តុលាការលើករណីជនជាប់ចោទ **អៀង ធីរិទ្ធ**។ បញ្ហាទាំងនោះ រួមមាន៖ (១)ការគោរពនូវគោលការណ៍ជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទ **អៀង ធីរិទ្ធ** ដែលជាបុគ្គលមានការប៉ះទង្គិចខ្លាំងផ្អែកអន់ខ្សោយខាងសមត្ថភាពបញ្ញាស្មារតី (២) ការកំណត់អំពីមធ្យោបាយដោះស្រាយសមស្រប (ឧទាហរណ៍៖ តើគួរពន្យារពេល ឬបញ្ឈប់សវនាការប្រឆាំងលើរូបលោកស្រី) (៣) ការបង្កើតនូវមូលដ្ឋានផ្លូវច្បាប់ដ៏ត្រឹមត្រូវនៅក្នុងការចេញបទបញ្ជាឲ្យមានការព្យាបាលតាមផ្អែកវេជ្ជសាស្ត្រ និង (៤) សេចក្តីសម្រេចថាតើវាជាការសម្រេចត្រឹមត្រូវតាមផ្លូវច្បាប់ដែលអាចទទួលយកបានក្នុងការបន្តការឃុំឃាំង ឬដោះលែងលោកស្រី (ទាំងមានលក្ខខណ្ឌ ឬមិនមានលក្ខខណ្ឌ)។

---

3 “The Trial Chamber held that it is in the interests of justice to sever the charges against the Accused Ieng Thirith in Case 002 pursuant to Internal Rule 89ter and to stay the proceedings against her.” Trial Chamber Decision, par.64. 23. ECCC Internal Rules, as revised 3 August 2011 [hereinafter, **INTERNAL RULES**]. Rule 89*ter* on Severance states that “When the interest of justice so requires, the Trial Chamber may at any stage order the separation ofproceedings in relation to one or several accused and concerning part of the entirety of the charges contained in an Indictment.”

4 Co-Prosecutors. “Immediate appeal against Trial Chamber Decision to order the release of accused Ieng Thirith” (18 November 2011). E138/1/1 [hereinafter, **IMMEDIATE APPEAL**].

5 Supreme Court Chamber. “Decision on immediate appeal against the Trial Chamber’s Order to release the accused Ieng Thirith” (13 December 2011). E138/1/7 [hereinafter, SUPREME COURT CHAMBER DECISION].

របាយការណ៍នេះ រួមមានការពិចារណានូវប្រធានបទនីមួយៗតាមលំដាប់លំដោយ ការពិគ្រោះនូវបញ្ហាពាក់ព័ន្ធផ្លូវច្បាប់ជាបទដ្ឋាន និងបញ្ហាផ្លូវច្បាប់មួយចំនួនដែលមានពីមុនៗមក ដោយធ្វើការសង្ខេបនូវសេចក្តីសម្រេចនានា និងការពិចារណារបស់តុលាការកំពូលដែលបានធ្វើកន្លងមក។

## ផ្នែកទី ២៖ សមត្ថភាពផ្លូវចិត្ត និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១១ មេធាវីការពារក្តីរបស់ជនជាប់ចោទ **អៀង ធីរិទ្ធ** បានសម្តែងនូវការព្រួយបារម្ភ ដែលសភាពផ្លូវចិត្តរបស់កូនក្តីខ្លួនបានបន្ទច់បង្អាក់នូវសមត្ថភាពនៃការមានរៀបរយដើម្បីត្រៀមខ្លួនចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការ។[6] អង្គជំនុំជម្រះសាលាដំបូង បានបង្គាប់ដល់វេជ្ជបណ្ឌិតចំនួន៥រូប ដើម្បីធ្វើការវាយតម្លៃស្ថានភាពជំងឺរបស់ជនជាប់ចោទរូបនេះ ដោយក្រុមវេជ្ជបណ្ឌិតទាំងនោះរួមមានវេជ្ជបណ្ឌិតជំនាញការផ្នែកឱសថ និងអ្នកជំនាញផ្នែកចិត្តសាស្ត្រមនុស្សចាស់ (វិកលវិទ្យា) ដែលមានជំនាញជាក់លាក់ផ្នែកជំងឺភ្លេចភ្លាំងបាត់ការចងចាំ។ វេជ្ជបណ្ឌិតទាំងនេះបានរកឃើញថា ជនជាប់ចោទ **អៀង ធីរិទ្ធ** មានសភាពវង្វេងវង្វាន់កាន់តែយ៉ាប់យ៉ឺនទៅៗ ដែលអាការៈបែបនេះអាចហៅបានថាជាជំងឺជរាភ្លេចភ្លាំង។[7] ប្រសិនបើការថមថយសមត្ថភាពផ្លូវចិត្តរារាំងលោកស្រីពីការអាចយល់បាននូវដំណើរការនីតិវិធី ឬការចូលរួមក្នុងកិច្ចការពារក្តីប្រកបដោយប្រសិទ្ធភាពនោះ មានន័យថាជនជាប់ចោទអាចនឹងមិនមានសម្បទាគ្រប់គ្រាន់នឹងធ្វើការជំនុំជម្រះបានឡើយ។ ទាំងច្បាប់របស់ **អ.វ.ត.ក** និងសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) គ្រប់គ្រាន់ឲ្យជនជាប់ចោទ **អៀង ធីរិទ្ធ** អាចជឿជាក់បានពីសិទ្ធិសំខាន់ៗក្នុងនាមជាចុងចោទម្នាក់ចំពោះសវនាការព្រហ្មទណ្ឌ ហើយការអនុលោមតាមខ្លះៗនូវសិទ្ធិជាមូលដ្ឋានគ្រឹះទាំងនេះប្រហែលជាមិនអាចសម្រេចបាន ក្នុងករណីដែលជនជាប់ចោទមានការចុះខ្សោយនូវសមត្ថភាពផ្នែកបញ្ញាស្មារតីយ៉ាងដូច្នេះឡើយ។

### ក. ការពន្យល់ពីសិទ្ធិទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌ និងសម្បទាជាបទដ្ឋាន៖ រដ្ឋអាជ្ញាទល់នឹងសំណុំរឿង *ស្ទ្រូហ្គា*

ទាំងបទដ្ឋានច្បាប់អន្តរជាតិ និងច្បាប់ **អ.វ.ត.ក** ផ្តល់ឲ្យចុងចោទទាំងឡាយនូវសិទ្ធិជាក់លាក់ក្នុងការជំនុំជម្រះ។ ឧទាហរណ៍ដូចជា សន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ក៏ដូចជាច្បាប់របស់ **អ.វ.ត.ក** បានបង្គាប់ថា ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សអត់ទោស ដ៏រាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។ ចំពោះការចោទប្រកាន់មកលើខ្លួនវិញ

---

6 REQUEST FOR NEUROPSYCHIATRIST, par. 36.

7 Geriatric Expert Professor A. John Campbell. "Report Prepared in Response to the Trial Chamber's Order Assigning Expert, Geriatric Expert Report – Mrs. IENGThirith" (23 June 2011). E62/3/6 [hereinafter, **GERIATRIC EXPERT REPORT** ]. par. 40. Trial Chamber Decision, par. 33 and 45.13 and 17.

ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នាសមស្របតាមមាត្រា១៤នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ឆ្នាំ១៩៦៦៖

ក) ទទួលព័ត៌មានភ្លាមៗ និងលម្អិតជាភាសាដែលខ្លួនយល់បានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន

ខ) មានពេលវេលា និងមានលក្ខណៈគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួនដែលជ្រើសរើសដោយខ្លួនឯង

គ) ត្រូវបានទទួលការជំនុំជម្រះដោយគ្មានការអូសបន្លាយ...[8]

បទបញ្ញាដូចមានចែងខាងលើនេះ គូសបញ្ជាក់ឲ្យឃើញថា ជនជាប់ចោទ **អៀង ធីរិទ្ធ** មានសិទ្ធិក្នុងការយល់ដឹងពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន ព្រមទាំងអាចចូលរួមក្នុងការដំណើរការនៃកិច្ចការពារក្តីរបស់ខ្លួន។ ប្រសិនបើគាត់មានសិទ្ធិពេញលេញក្នុងការទទួលបាននូវការជូនដំណឹងជាមុនអំពីបទចោទទាំងឡាយប្រឆាំងនឹងខ្លួន ថាតើមានភាសា បញ្ហាផ្លូវចិត្ត ឬឧបសគ្គផ្សេងពីនេះដែលប៉ះពាល់ដល់ការយល់ដឹងរបស់គាត់។ ការពង្រីកនូវអត្ថន័យនៃសិទ្ធិនៃការមាន "លក្ខណៈពេញលេញ" ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួន គួរតែរួមបញ្ចូលជាចាំបាច់ដោយខានមិនបាននូវសមត្ថភាពក្នុងការចូលរួម សមត្ថភាពនៃការរៀបចំ និងសមត្ថភាពក្នុងការទាក់ទងជាមួយមេធាវីការពារក្តីរបស់ខ្លួនគ្រប់ពេលវេលាដែលគាត់ត្រូវការ។ ភាពអាចយល់បាន គឺថាសិទ្ធិទាំងនេះអាចនឹងប៉ះពាល់ដល់ស្ថានភាពរបស់ជនជាប់ចោទ **អៀង ធីរិទ្ធ** ដូច្នេះដែរ ដោយកំណត់នូវសមត្ថភាពនៃការចងចាំរបស់គាត់ សមត្ថភាពនៃការយល់បាន និងភាពអាចយល់ដឹងពីស្ថានភាពជម្ងឺផ្ទាល់ខ្លួនរបស់គាត់។

តុលាការព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គូស្លាវី (ICTY) បានប្រឈមមុខនឹងបញ្ហាស្រដៀងគ្នានេះចំពោះរដ្ឋអាជ្ញាទល់នឹងសំណុំរឿង ***ស្ទ្រូហ្គា*** ។ ក្នុងសំណុំរឿងនោះ ចុងចោទ ***ផាវលេ ស្ទ្រូហ្គា*** (Pavle Strugar) ត្រូវបានវិនិច្ឆ័យថាមានជម្ងឺវង្វេងវង្វាន់ស្មារតីដោយសារខូចសរសៃឈាមក្នុងខួរក្បាល។ ជម្ងឺវង្វេងវង្វាន់ស្មារតី គឺជាទម្រង់ជម្ងឺសាមញ្ញទីពីរនៃភាពវង្វេងវង្វាន់បន្ទាប់ពីជម្ងឺភ្លេចភ្លាំង។ ជម្ងឺនេះបង្កឡើងដោយសារការផ្គត់ផ្គង់ឈាមមិនគ្រប់គ្រាន់ទៅកាន់ខួរក្បាល។ រោគសញ្ញាមួយចំនួនរួមមានដូចជា៖ ការបាត់បង់ការចងចាំ ការផ្លាស់ប្តូរអារម្មណ៍ញឹកញាប់ និងបញ្ហាផ្សេងៗទៀតរួមផ្សំជាមួយនឹងកង្វះខាតនៃភាសានិយាយស្តី ការលើកហេតុផលនានា និងការធ្វើការសម្រេចចិត្ត។[9] នៅក្នុងសំណុំរឿង ***ស្ទ្រូហ្គា*** សាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គូស្លាវីបានរកឃើញថា ការវិភាគរករោគវិនិច្ឆ័យទៅលើការមានសម្បទាគ្រប់គ្រាន់នៅក្នុងការជំនុំ

---

[8] Law on the Establishment of Extraordinary Chambers in the Courts of Cambodia for the Prosecution of Crimes Committed During the Period of Democratic Kampuchea, as amended. NS/RKM/1004/006 (27 October 2004) Oct. 27, 2004 [hereinafter, **ECCC LAW**].Article 35 new, (a), (b), (d). Also, International Covenant on Civil and Political Rights (16 December 1966) [hereinafter, **ICCPR**]. Article 14(3) (a), (b), (d).

[9] Alzheimer's Society. "What is vascular dementia? Factsheet 402." Available at <http://alzheimers.org.uk/site/scripts/documents_info.php?documentID=161>, accessed 23 July 2012.

ជម្រះ "គឺមិនបានកំណត់ព្រំដែនដើម្បីបង្កើត ឬធ្វើឲ្យមានឡើងថាតើភាពឥតរបៀបរៀបរយណាមួយគឺកំពុងតែកើតមាននោះទេ...ប៉ុន្តែវាជាការប្រសើរជាង ចំពោះការដែលបានតម្រង់ទិសដៅមួយដើម្បីសម្រេចចិត្តថាតើគាត់អាចប្រើប្រាស់សិទ្ធិរបស់គាត់ ដោយមានប្រសិទ្ធភាពនៅក្នុងដំណើរការនីតិវិធីប្រឆាំងនឹងរូបខ្លួនដែរឬអត់"។ [10] សាលាដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គូស្លាវី និងសាលាឧទ្ធរណ៍បានវិភាគនូវលក្ខន្តិកៈច្បាប់ពាក់ព័ន្ធជាមួយនឹងយុត្តិសាស្ត្រពីតុលាការអន្តរជាតិដទៃទៀត ក៏ដូចជាច្បាប់ជាយុត្តាធិការ ច្បាប់ជាតិស៊ីវិល និងច្បាប់ធម្មតា[11] ដើម្បីចងក្រងនូវបញ្ជីរាយសិទ្ធិដែលចាំបាច់ស្តីពីលក្ខន្តិកៈ ក្នុងការកំណត់សម្បទារបស់ជនជាប់ចោទក្នុងការជំនុំជម្រះ។ តុលាការបានកត់សម្គាល់ថា យ៉ាងហោចណាស់មានសមត្ថភាពផ្លូវចិត្តចំនួនប្រាំពីរ ដែលពាក់ព័ន្ធនឹងសិទ្ធិទទួលបាននូវការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌។ សមត្ថភាពទាំងនោះ រួមមានដូចខាងក្រោមនេះ៖

- សមត្ថភាពឆ្លើយតបទៅនឹងបទចោទ
- សមត្ថភាពយល់ដឹងអំពីលក្ខណៈនៃការចោទប្រកាន់
- សមត្ថភាពយល់ដឹងអំពីការប្រព្រឹត្តទៅនៃដំណើរការនីតិវិធី
- សមត្ថភាពយល់ដឹងអំពីសេចក្តីពិស្តារនៃភស្តុតាង
- សមត្ថភាពណែនាំមេធាវីការពារក្តីរបស់ខ្លួន
- សមត្ថភាពយល់បានអំពីផលវិបាកនៃដំណើរការនីតិវិធី និង
- សមត្ថភាពក្នុងការធ្វើសក្ខីកម្មនៃជនជាប់ចោទ[12]

សមត្ថភាពទាំងនេះ ជាធម្មតាត្រូវបានសំដៅទៅលើលក្ខន្តិកៈនៃ *ស្ទ្រូហ្គា* និងត្រូវបានប្រើប្រាស់ [13] ជាមគ្គុទ្ទេសក៍ក្នុងការសន្និដ្ឋាននូវសម្បទារបស់ជនជាប់ចោទក្នុងការជំនុំជម្រះ។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះតុលាការព្រហ្មទណ្ឌអន្តរជាតិអតីតប្រទេសយូហ្គូស្លាវីបានគូសបញ្ជាក់យ៉ាងច្បាស់លាស់ថា "វានឹងមិនមានភាពសមរម្យទាល់តែសោះ ហើយក៏មិនត្រឹមត្រូវតាមទំនៀមទំលាប់

---

[10] *The Prosecutor v. PavleStrugar*. IT-01-42-A. ICTY Trial Chamber II."Decision Re the Defence Motion to Terminate Proceedings" (26 May 2004). [Hereinafter, ***STRUGAR*TRIAL CHAMBER DECISION**]. par. 35.

[11] This included the ICTY, International Criminal Tribunal for Rwanda, International Military Tribunal, European Court of Human Rights, International Criminal Court, Special Court for Sierra Leone, Special Panels for Serious Crimes in East Timor, Australian, Canadian, Indian, Malaysian, United States, Austrian, Japanese, Korean, Dutch, German, Russian, Bosnian, Croatian and Serbian law and precedents. *The Prosecutor v.PavleStrugar*. IT-01-42-A. ICTY Appeals Chamber. "Judgment" (17 July 2008). [Hereinafter, ***STRUGAR*APPEALS CHAMBER JUDGMENT**]. par. 45-54.

[12] *STRUGAR*TRIAL CHAMBER DECISION, par. 2, "Capacities of an accused"; *STRUGAR*APPEALS CHAMBER JUDGMENT,par. 41.

[13] The *Strugar*criteria have most often been used at the ICTY. However, other international criminal courts have also used the criteria: the International Criminal Tribunal for Rwanda (ICTR) in *Prosecutor v. Karemera et al* and *Gacumbitsi v.Prosecutor*; Special Court for Sierra Leone (SCSL) in *Prosecutor v. Taylor*, SCSL-2003-01-T, Trial Chamber II, "Defense Application to Exclude the Evidence of Proposed Prosecution Expert Witness Corinne Dufka or, in the alternative, to Limit Its Scope" (28 January 2008); Special Panels for Serious Crimes in Dili, East Timor, in *Deputy General Prosecutor for Serious Crimes v. JosepNahak*, No. 01A/2004, Dili District Court before Judge Phillip Rapoza, "Findings and Order on Defendant Nahak's Competence to Stand Trial" (1 March 2005). par. 28-29.

ដែលបានធ្វើពីមុនមកដែរ ព្រមទាំងមានលក្ខណៈប្រតិនិក្ខេប (ភាពផ្ទុយដាច់ស្រឡះ) ទៅនឹងការអនុវត្តនៃតុលាការព្រហ្មទណ្ឌអន្តរជាតិផងដែរ ដែលតម្រូវថាសមត្ថភាពនីមួយៗ ដូចមានចែងខាងលើត្រូវតែមានវត្តមាននៅក្នុងតុលាការជាតិកម្រិតខ្ពស់បំផុត ឬតុលាការកម្រិតខ្ពស់បំផុតផ្សេងៗទៀត ដែលជនជាប់ចោទជាក់លាក់ណាម្នាក់ធ្លាប់បានអាស្រ័យផល...ដ៏សមគួរ...អ្វីដែលត្រូវការជាបទដ្ឋានអប្បបរមាមួយគឺសមត្ថភាពទាំងមូល ដែលជនជាប់ចោទម្នាក់មិនអាចនឹងធ្វើសវនាការបានឡើយបើមិនមានភាពយុត្តិធម៌ ឬមិនមានលក្ខណៈត្រឹមត្រូវតាមច្បាប់ដែលបានចែង”។[14] យន្តការនេះបានទុកចន្លោះផ្លូវយ៉ាងច្រើនដល់សេរីភាពនៃយុត្តាធិការក្នុងសំណុំរឿងបន្តបន្ទាប់ទៀត។[15]

ម្យ៉ាងវិញទៀត តុលាការព្រហ្មទណ្ឌអន្តរជាតិអតីតប្រទេសយូហ្គូស្លាវីបានរកឃើញថា វត្តមានមេធាវីប្រឹក្សាជាជំនួយដែលអាចបំពេញបន្ថែមយ៉ាងគ្រប់គ្រាន់ ទៅលើរាល់ការខ្វះចន្លោះនៃសមត្ថភាពពាក់ព័ន្ធនានានៃការអនុវត្តសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។[16] ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះបានឲ្យដឹងថា ការប្រើប្រាស់មេធាវីខ្លួនបានគឺតម្រូវឲ្យជនជាប់ចោទមានសមត្ថភាពអាចណែនាំមេធាវីប្រកបដោយប្រសិទ្ធភាព សម្រាប់ជាគោលបំណងនៃការជំនុំជម្រះប្រកបដោយយុត្តិធម៌នេះ។[17]

## ខ. សមត្ថភាពផ្លូវចិត្តរបស់ជនជាប់ចោទ អៀង ធីរិទ្ធ

អង្គជំនុំជម្រះសាលាដំបូង បានកោះហៅអ្នកជំនាញផ្នែកឱសថមនុស្សចាស់ និងអ្នកជំនាញផ្នែកវិកលវិទ្យាបួនរូបដើម្បីកំណត់ឲ្យបានថាតើជនជាប់ចោទ **អៀង ធីរិទ្ធ** អាចមានកាយសម្បទាគ្រប់គ្រាន់ក្នុងការជំនុំជម្រះក្តីដែរឬយ៉ាងណា។ អ្នកជំនាញការផ្នែកមនុស្សចាស់បានធ្វើការសន្និដ្ឋានផ្នែកជំងឺភ្លេចភ្លាំង និងជំងឺវង្វេងវង្វាយ រីឯអ្នកជំនាញការផ្នែកស្មារតីបួនរូបបានបំពេញការងារផ្នែកសតិវិទ្យាផ្នែកវិទ្យាមនុស្សចាស់ ផ្នែកវិកលវិទ្យា និងធ្វើការសន្និដ្ឋាននូវកម្រិតយល់ដឹងក្នុងប្រទេសកម្ពុជា និងក្រៅប្រទេសផងដែរ។[18]

អ្នកជំនាញការទាំងប្រាំរូបបានទទួលស្គាល់ថា ជនជាប់ចោទ **អៀង ធីរិទ្ធ** “ទទួលរងនូវជំងឺវង្វេងស្មារតីធ្ងន់ធ្ងរ”។[19] ពួកគាត់បានរកឃើញថា ការអន់ថយទាំងឡាយដែលពាក់ព័ន្ធគឺថា “ជនជាប់ចោទមិនមានសមត្ថភាពក្នុងការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ឡើយ ការ

---

14 *STRUGAR*TRIAL CHAMBER DECISION, par. 37.

15 Ibid. The Chamber also used the following language: a chamber must view the accused's capacities “overall and in a reasonable and commonsense manner” (par. 3); a decision on an accused's fitness is “merely the balance of probabilities” (par. 4); an accused must be able to “sufficiently” exercise his rights (par. 3) at a “minimum standard of overall capacity” (par. 37).

16 “The availability of counsel… may well adequately compensate for any deficiency of a relevant capacity.” Ibid, par. 22; also cited in TRIAL CHAMBER DECISION, par. 28. 11.

17 “The use of counsel requires, however, that the accused has the capacity to be able to instruct counsel sufficiently for this purpose.” *STRUGAR*TRIAL CHAMBER DECISION, par. 22; also cited in TRIAL CHAMBER DECISION, par. 28. 11.

18 Pursuant to Internal Rule 32: “The Co-Investigating Judges or the Chambers may, for the purpose of determining whether a Charged Person or Accused is physically and mentally fit to stand trial, or for any other reasons, or at the request of a party, order that they undergo a medical, psychiatric or psychological examination by an expert. The reasons for such order, and the report of the expert, shall be recorded in the case file.”

19 GERIATRIC EXPERT REPORT, par. 40.

តម្រូវឲ្យជនជាប់ចោទចូលរួមសវនាការគឺមិនមែនជាការត្រឹមត្រូវទេ”។[20] អ្នកជំនាញទាំងនេះ បានសំដៅលើទ្រង់ទ្រាយជាក់លាក់នៃភាពចុះខ្សោយរបស់លោកស្រីដែលប៉ះពាល់ដល់សិទ្ធិក្នុងការជំនុំជម្រះប្រកបដោយយុត្តិធម៌ដូចបានពន្យល់ក្នុងសំណុំរឿង *ស្ទូហ្គា* ។ ក្រុមអ្នកជំនាញបានកត់សម្គាល់ថា លោកស្រីចងចាំនូវការណាត់ជួបមួយចំនួនជាមួយនឹងអ្នកប្រឹក្សាផ្នែកច្បាប់ ក៏ប៉ុន្តែមិនបានចងចាំផ្នែកផ្សេងពីនេះឡើយ។[21] គាត់អាចមាននឹកឃើញទេ ដែលថាគាត់ធ្លាប់ជារដ្ឋមន្ត្រីក្រសួងមួយរូប[22] គាត់មិនអាចចងចាំនូវខ្លឹមសារជារួម នៅក្នុងសវនាការដំបូងជាមួយអង្គជំនុំជម្រះសាលាដំបូងឡើយ ហើយក៏មិនមានការចងចាំនូវបទចោទមួយចំនួនប្រឆាំងលើរូបខ្លួនដែរ។[23] ម្យ៉ាងវិញទៀត អ្នកជំនាញទាំងនេះបានរកឃើញថា ដោយសារការរវើរវាយរបស់គាត់ ធ្វើឲ្យគាត់មានការចុះខ្សោយនូវសមត្ថភាពអាចយល់បាននូវសំណួរទាំងឡាយ ការធ្វើតាមការណែនាំផ្សេងៗ ការរំលឹកឡើងវិញនូវព្រឹត្តិការណ៍មួយចំនួន ការផ្ទង់អារម្មណ៍ និងការរក្សានូវការគិតដោយមិនផ្លាស់ប្តូរ។[24] តាមការដែលបានលើកឡើងនេះ ក្រុមអ្នកជំនាញបានគិតថា លោកស្រី **អៀង ធីរិទ្ធ** អាចនឹងមានការលំបាកក្នុងការធ្វើការណែនាំដល់មេធាវីប្រឹក្សាក្តីរបស់ខ្លួន ការលំបាកក្នុងការផ្តល់សក្ខីកម្ម និងការយល់ដឹងអំពីមូលហេតុនៃបទចោទប្រកាន់ទាំងឡាយចំពោះរូបគាត់ បូករួមទាំងការយល់បានពីដំណើរការសវនាការ ភាពពិស្តារនៃភស្តុតាង ក៏ដូចជាហេតុបច្ច័យដែលបានពីការធ្វើសវនាការផងដែរ ដែលបញ្ហាទាំងនេះជាលក្ខខណភស្តុតាងវិនិច្ឆ័យរបស់ ***ស្ទូហ្គា*** ដើម្បីកំណត់បានពីសម្បទាក្នុងការជំនុំជម្រះ។

យោងតាមរបាយការណ៍ទាំងនេះ ក្រុមអ្នកជំនាញទាំងប្រាំទំនងជាមិនបានគិតថា លោកស្រី **អៀង ធីរិទ្ធ** មានសមត្ថភាពផ្លូវចិត្តពេញលេញនៅក្នុងការប្រើប្រាស់សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌យ៉ាងមានប្រសិទ្ធភាពនោះទេ។ ក្រុមការពារក្តីរបស់លោកស្រី **អៀង ធីរិទ្ធ** បានគាំទ្រនូវការទាមទារនេះ ត្រង់ចំណុចដែលថាលោកស្រី **អៀង ធីរិទ្ធ** មិនមានសម្បទាក្នុងការណែនាំមេធាវីប្រឹក្សាក្តីក្នុងការរៀបចំការពារខ្លួន។[25] អ្នកជំនាញទាំងអស់នោះបានចាត់ទុកថា លោកស្រី **អៀង ធីរិទ្ធ** ដូចជាមិនអាចធ្វើពុត ឬក្លែងបន្លំ បានពីស្ថានភាពជំងឺវង្វេងវង្វាន់របស់លោកស្រីបានឡើយ។[26] លើសពីនេះទៀត អ្នកជំនាញទាំងអស់បានរកឃើញថា វាហាក់ដូចជាមិនអាចទៅរួចទេ

---

[20] Ibid, par. 41. See also, TRIAL CHAMBER DECISION, par. 50, 18, citing Psychiatrists. “Expertise Report Prepared in Response to the Trial Chamber’s Expertise Order E111, 23 August 2011” (9 October 2011). E111/8 [hereinafter, **PSYCHIATRIC EXPERTS REPORT**].par. 43. Original Psychiatric Experts Report unavailable.

The four psychiatric experts found that her “cognitive impairment would compromise the ability to understand what was said in court, reason and weigh information, and comment intelligibly on it. Specifically… she would not be able to retain information form any statement made in court long enough to be able to comment on them intelligibly.”

[21] Ibid, par. 13.

[22] Ibid, par. 14.

[23] Ibid. The expert geriatrician said she “does not recall she was a Minister” nor “the date of victory of the regime” (par. 14), she does not remember the number of siblings or children she has (par. 19), and she “could not remember the first hearing, had no memory of the charges and said there were no accusations against her (par. 22). The psychiatric experts also found she would not be able to instruct her counsel or assist in the preparation of her defense “due to her memory impairment, not only in relation to her involvement at the time of the alleged offences, but memories for the wider context of her life at the time.” (PSYCHIATRIC EXPERTS REPORT, par. 45, cited in TRIAL CHAMBER DECISION, par. 51. 18.)

[24] GERIATRIC EXPERT REPORT, par. 34.

[25] REQUEST FOR NEUROPSYCHIATRIST, par. 36; TRIAL CHAMBER DECISION, par. 19, which cites transcript from hearing 20 October 2011, p. 103.

[26] TRIAL CHAMBER DECISION, par. 52. 19.

ដែលជនជាប់ចោទ **អៀង ធីរិទ្ធ** អាចជាសះស្បើយបានពីជំងឺប្រភេទនេះ និងអាចមានសម្បទាពេញលេញក្នុងការជំនុំជម្រះក្តី។[27]

### គ. សេចក្តីសន្និដ្ឋានស្តីពីសម្បទាក្នុងការជំនុំជម្រះរបស់លោកស្រី អៀង ធីរិទ្ធ ក្រោមលក្ខខណ្ឌនៃរោគវិនិច្ឆយក្នុងករណី *ស្ត្រូហ្គា*

ផ្អែកតាមយោបល់មួយចំនួនរបស់អ្នកជំនាញការ [28] និងផ្អែកតាមលទ្ធផលនៃសវនាការរបស់អង្គជំនុំជម្រះស្តីពីប្រធានបទនេះ[29] អង្គជំនុំជម្រះបានរកឃើញថា អ្នកស្រី **អៀង ធីរិទ្ធ** មានការខ្វះខាតនូវសមត្ថភាពជាច្រើនដែលបានរៀបរាប់ក្នុងករណី*ស្ត្រូហ្គា*។[30] អង្គជំនុំជម្រះ បានរកឃើញថាដោយសារតែ "លោកស្រី **អៀង ធីរិទ្ធ** មិនអាចប្រើប្រាស់មូលដ្ឋានគ្រឹះនៃសិទ្ធិក្នុងការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដោយមានអត្ថន័យថាបញ្ហានេះក៏មិនអាចផ្អែកតាមបទដ្ឋានអន្តរជាតិដែលបានចង្អុលបង្ហាញក្នុងសេចក្តីសម្រេចនៃសំណុំរឿង*ស្ត្រូហ្គា* ដែរ។ អង្គជំនុំជម្រះមិនមានយន្តការ ឬសេចក្តីសម្រេចផ្សេងពីនេះទេ ប៉ុន្តែបានចេញសេចក្តីប្រកាសស្តីពីការមិនមានសម្បទាគ្រប់គ្រាន់ក្នុងការជំនុំជម្រះក្តី"[31] អង្គជំនុំជម្រះបានរកឃើញថា "ការធ្វើសវនាការ និងការបន្តឃុំខ្លួនលើជនជាប់ចោទដែលមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការយល់ដឹងពីដំណើរការសវនាការប្រឆាំងលើរូបលោកស្រី ឬដើម្បីបានការចូលរួមប្រកបដោយអត្ថន័យក្នុងកិច្ចការពារខ្លួនដោយផ្ទាល់ នឹងមិនបានបម្រើផលប្រយោជន៍អ្វីដល់ភាពយុត្តិធម៌ឡើយ" [32] ហេតុដូច្នេះហើយទើបបំបែកសណុំរឿងលោកស្រីចេញពីជនជាប់ចោទផ្សេងទៀតក្នុងសំណុំរឿង០០២។

ភាគីសហព្រះរាជអាជ្ញាមិនបានប្តឹងឧទ្ធរណ៍ចំពោះអង្គហេតុដែលថាលោកស្រី **អៀង ធីរិទ្ធ** ត្រូវបានចាត់ទុកថាមិនមានសម្បទានៅក្នុងការជំនុំជម្រះឡើយ។ ចំពោះករណីនេះ អង្គជំនុំជម្រះតុលាការកំពូលក៏មិនដែលបានធ្វើសេចក្តីសម្រេចនៃញត្តិណាមួយលើបញ្ហានេះដែរ។

---

[27] The Psychiatric Experts noted the "gradual insidious decline" of her condition. Furthermore, "they commented that Alzheimer's disease is not a reversible form of dementia." TRIAL CHAMBER DECISION, par. 70, citing Psychiatric Experts' Report, par. 36 and Transcript 19 October 2011, p. 129.

[28] GERIATRIC EXPERT REPORT; Geriatric Expert. "Follow Up Report Concerning Mrs. IENGThirith in Accordance to Trial Chamber's Expertise Order E62/3, 4 April 2011" (26 August 2011). E62/3/12 [hereinafter, **FOLLOW-UP REPORT OF GERIATRICIAN**]; PSYCHIATRIC EXPERTS' REPORT.

[29] From 21 February 2011 to 17 November 2011, the Trial Chamber heard written and oral arguments regarding IengThirith's fitness to stand trial.

[30] The Trial Chamber said IengThirith "may still possess some capacity to enter a plea, to understand the charges against her, to understand the details of evidence, and to testify. However, the Acccused's impaired memory will likely impact upon her ability to accurately recall events that occurred between 1975 and 1979."(TRIAL CHAMBER DECISION, par. 57. 21.) In addition, she "lacks the capacity to understand the proceedings against her and… [to] participate meaningfully in her own defence." (TRIAL CHAMBER DECISION, par. 65. 24.) The *Strugar* criteria includes all of these capacities as specific qualities to be evaluated when considering if an accused is fit to stand trial.

[31] TRIAL CHAMBER DECISION, par. 59. 21.

[32] Ibid, par. 60. 21-22.

## ផ្នែកទី ៣៖ ការផ្អាក ឬបញ្ឈប់ដំណើរការសវនាការ

បន្ទាប់ពីអង្គជំនុំជម្រះរកឃើញថា លោកស្រី **អៀង ធីរិទ្ធ** មិនមានកាយសម្បទាគ្រប់គ្រាន់ក្នុងការជំនុំជម្រះ តុលាការត្រូវតែសម្រេចថាតើវាស្ថិតនៅក្នុងការសម្របសម្រួលរបស់ខ្លួនដើម្បីផ្អាក ឬបញ្ឈប់ដំណើរការនីតិវិធី និងធ្វើការកំណត់ថាតើដំណោះស្រាយសមរម្យអ្វីខ្លះដែលត្រូវបានផ្តល់ឲ្យក្នុងឱកាសនៃសំណុំរឿងមួយនេះ។ អង្គជំនុំជម្រះបានជ្រើសរើសក្នុងការផ្អាកដំណើរការនីតិវិធី ជាជាងបញ្ឈប់ដំណើរការសវនាការទាំងស្រុងប្រឆាំងនឹងលោកស្រី **អៀង ធីរិទ្ធ**។ ទោះជាយ៉ាងនេះក្តី មានការពិភាក្សាខ្លះៗលើបញ្ហានៃការសរសេរសេចក្តីសម្រេចពីតុលាការជាលាយលក្ខណ៍អក្សរ។[33]

ក្នុងការតវ៉ា មេធាវីការពារក្តីបានទាមទារថា ការរក្សាទុកនូវបទចោទទាំងឡាយ បានប៉ះពាល់ដល់ការបញ្ឈប់ដំណើរការសវនាការប្រឆាំងនឹងលោកស្រី **អៀង ធីរិទ្ធ** ក៏ប៉ុន្តែភាគីសហព្រះរាជអាជ្ញាបានតវ៉ាថា ការប៉ះពាល់ដល់ការបញ្ឈប់សវនាការ អាចនឹងមិនសមស្របក្នុងដំណាក់កាលនេះ។[34] តុលាការកំពូលបានធ្វើការសង្កេតត្រង់ចំណុចនេះថា សេចក្តីសម្រេចលើបញ្ហានេះ ជាឆន្ទានុសិទ្ធិរបស់តុលាការ ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានចែងពីអំណាចរបស់ចៅក្រមក្នុងការបង្អង់ ឬផ្អាកកិច្ចដំណើរការនីតិវិធីសវនាការ "ក្នុងកាលៈទេសៈមួយចំនួនដែលជាឧបសគ្គដល់ការបន្តកិច្ចដំណើរការនីតិវិធី" ។[35] នៅក្នុងសេចក្តីសម្រេចចុងក្រោយលើបញ្ហានេះ តុលាការកំពូលបានផ្តោតសំខាន់ថាតើអត្ថន័យនៃពាក្យ "ផ្អាក" ចេញដោយអង្គជំនុំជម្រះផ្តល់នូវលទ្ធភាពដែលសវនាការអាចនឹងបន្តនៅពេលក្រោយណាមួយ។ យោងតាមតុលាការកំពូល "ការផ្អាកសវនាការដែលមិនមានភាពច្បាស់លាស់អំពីការបន្តដំណើរការនីតិវិធី គឺពិតជាមានអានុភាពបញ្ចប់កិច្ចដំណើរការនីតិវិធីមិនឲ្យបន្តទៀត និងរារាំងដល់ការចេញសាលក្រមលើអង្គសេចក្តី"។[36]

ក្រឡេកមើលយុត្តាធិការនៃក្រមព្រហ្មទណ្ឌអន្តរជាតិពីបណ្តាតុលាការមួយចំនួន ដើម្បីបាននូវការណែនាំខ្លះៗ អង្គជំនុំជម្រះបានកត់សម្គាល់ថា នៅពេលដែលបុគ្គលម្នាក់ត្រូវបានចោទប្រកាន់តុលាការអន្តរជាតិមួយចំនួន ជាញឹកញាប់បានពន្យារពេលដំណើរការនីតិវិធីជាជាងបញ្ឈប់តែម្តង បំណងដើម្បីប្រើឲ្យអស់នូវគ្រប់លទ្ធភាពដែលអាចធ្វើទៅបានក្នុងការកាត់ទោស បើទោះណាជានៅពេលដែលជនជាប់ចោទបានទទួលរងនូងបញ្ហាផ្នែកសុខភាពធ្ងន់ធ្ងរយ៉ាងណាក្តី។[37]

អង្គជំនុំជម្រះបានទាញយកចំណុចសំខាន់នៃសំណុំរឿងរបស់ *Djukić*, *Kovačević* និងសំណុំរឿងរបស់ *Tadić* ពីតុលាការព្រហ្មទណ្ឌអន្តរជាតិអតីតប្រទេសយូហ្គូស្លាវី។ នៅពេលដែល Djordje Djukić បានចូលខ្លួនក្នុងសវនាការ គាត់បានស្ថិតក្នុងដំណាក់កាលចុងក្រោយនៃជំងឺរបស់

---

[33] Ibid, par. 61, 64. 22, 23.
[34] IMMEDIATE APPEAL, Section II (B)(i), p. 2.
[35] Code of Criminal Procedure of the Kingdom of Cambodia (2008).[Hereinafter, **CAMBODIAN CODE OF CRIMINAL PROCEDURE**]. Articles 343, 345, 310, Cited in SUPREME COURT DECISION, par. 17.
[36] SUPREME COURT DECISION, par. 15. 9.
[37] Ibid, par. 19. 11.

ខ្លួន។ អង្គជំនុំជម្រះ បានសម្រេចចិត្តដោះលែងចុងចោទជាបណ្ដោះអាសន្នក្រោមហេតុផលនៃបញ្ហាមនុស្សធម៌។ ទោះជាយ៉ាងណា ដំណើរការសវនាការលើរូបគាត់មិនបានបញ្ឈប់រហូតទាល់តែគាត់ស្លាប់ ហើយអង្គជំនុំជម្រះបានបដិសេធនូវសំណើជាក់លាក់មួយចំនួនដើម្បីដកចេញនូវសំណើបញ្ជូនរឿងទៅជំនុំជម្រះ បើទោះបីជាបាននិយាយថា សំណើទាំងឡាយបានមកពីទាំងភាគីអយ្យការ និងភាគីការពារក្ដីក៏ដោយ។[38] សំណុំរឿងរបស់ Djukić ត្រូវបានបញ្ឈប់ក្នុង១១ថ្ងៃ ក្រោយការស្លាប់របស់ជនជាប់ចោទរូបនេះ។ រីឯ Vladimir Kovačević ក៏មានបញ្ហាផ្លូវចិត្ត[39] ដែលកំណត់ព្រំដែនសមត្ថភាពរបស់គាត់ក្នុងការអនុវត្តសិទ្ធិក្នុងការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ យោងតាមបទដ្ឋានស្រដៀងគ្នានឹងករណីមួយដែលបានលើកឡើងក្នុងសំណុំរឿង*ស្ត្រូហ្គា*។[40] ក្នុងសំណុំរឿងរបស់គាត់ អង្គជំនុំជម្រះបានដោះលែងជនជាប់ចោទជាបណ្ដោះអាសន្នទៅកាន់ប្រទេស **ស៊ែប៊ីយ៉ា** (Serbia)។ សំណុំរឿងរបស់គាត់មិនត្រូវបានបញ្ឈប់ទេ តែបានបញ្ជូនទៅកាន់ប្រព័ន្ធយុត្តិធម៌នៃប្រទេស **ស៊ែប៊ីយ៉ា**។[41] Momir Tadić ត្រូវបានដោះលែងជាបណ្ដោះអាសន្នបន្ទាប់ពីសវនាការរបស់គាត់ត្រូវបានពន្យាររយៈពេល៩ខែដោយសារបញ្ហាសុខភាព។ គាត់បានស្លាប់ប្រាំបីខែក្រោយមក ហើយសំណុំរឿងរបស់គាត់ត្រូវបានបញ្ឈប់ក្នុងអំឡុង ១៥ថ្ងៃបន្ទាប់ពីការស្លាប់។[42]

អង្គជំនុំជម្រះនៃតុលាការកំពូលបានរកឃើញថា បទពិសោធន៍ដែលធ្លាប់មានពីមុនៗមកបានអនុគ្រោះឲ្យមាននូវការពន្យារនូវសវនាការជាជាងការបញ្ឈប់។ តុលាការបានរកឃើញថា ការខកខានក្នុងការឆ្លើយតបចំពោះឧបសគ្គមួយដែលរាំងស្ទះដល់កិច្ចដំណើរការសវនាការគឺការពន្យារពេលដំណើរការនីតិវិធី ឯការបញ្ឈប់អាចនឹងសមស្របចំពោះតែក្រោយការស្លាប់របស់ជនជាប់ចោទ ឬក៏បន្ទាប់ពីលក្ខន្តិកៈនៃការព្រំដែនកំណត់ត្រូវបានដំណើរការក្នុងបទឧក្រិដ្ឋមួយ។[43] ម្យ៉ាងវិញទៀត អង្គជំនុំជម្រះនៃតុលាការកំពូលបានលើកហេតុផលថា ទាំងសាធារណជន ទាំងជនរងគ្រោះ ទាំងភាគីការពារក្ដី និងភាគីសហព្រះរាជអាជ្ញាបានទទួលផលប្រយោជន៍មួយក្នុងការអនុញ្ញាតឲ្យមានលទ្ធភាពដែលអាចធ្វើទៅបាននៃការបន្តដំណើរការសវនាការ។ អង្គជំនុំជម្រះបានថ្លែងថា “វាជាអត្ថិភាពនៃផលប្រយោជន៍សាធារណៈ...នៅក្នុងការប្ដឹងចោទប្រកាន់ជនជាប់ចោទ។ អត្ថិភាពតែមួយគត់របស់តុលាការនេះ...គឺជាសក្ខីភាពចំពោះផលប្រយោជន៍សាធារណៈយ៉ាងធំធេង នៅក្នុងការកាត់សេចក្ដី

---

38 Ibid, *citingProsecutor v. DjordjeDjukić.* IT-96-20-T. ICTY Trial Chamber I. “Decision Rejecting the Application to Withdraw the Indictment and Order for Provisional Release” (24 April 1996). [Hereinafter, ***DJUKIĆ*DECISION**] stated “neither the Statute nor the Rule authorize the withdrawal of an indictment for medical reasons, no matter how serious, for the major crimes over which the Tribunal has jurisdiction.” *Prosecutor v. DjordjeDjukić.* IT-96-20-T. ICTY Prosecution. “Prosecutor’s Motion to Withdraw Djukić’s Indictment” (19 April 1996). The Prosecutor argued that it would be “unjust and inhumane” to force the defendant to stand trial when he was suffering from a terminal disease.

39 Condition unknown. Redacted from the document for confidentiality reasons.

40 *Prosecutor v. Kovačević.* IT-01-42/2-1. ICTY Trial Chamber I.“Public Version of the Decision on Accused’s Fitness to Enter a Please and Stand Trial” (12 April 2006).par. 5.

41 Kovačević’s case has since been referred to the Serbian judicial system and awaits trial. “Kovačević Case Information Sheet.” Available at <http://www.icty.org/x/cases/kovacevic_vladimir/cis/en/cis_kovacevic_vladimir.pdf>, accessed 23 July 2012.

42 “Tadić Case Information Sheet,” pp. 3-4. Available at <http://www.icty.org/x/cases/talic/cis/en/cis_talic_en.pdf>, accessed 23 July 2012.

43 SUPREME COURT DECISION, par. 18. 10.

បុគ្គលទាំងឡាយ និងឧក្រិដ្ឋកម្មក្នុងយុត្តាធិការរបស់ខ្លួន ដើម្បីទប់ស្កាត់នូវនិទណ្ឌភាព និងជម្រុញនូវការផ្សះផ្សាជាតិ”។[44] អង្គជំនុំជម្រះក៏បានតវ៉ាថា ព្រោះតែក្រុមការពារក្តីបានជជែកការពារថាមិនបានធ្វើអ្វីខុស ពួកគេមានផលប្រយោជន៍ផ្លូវច្បាប់ដើម្បីធ្វើបទបង្ហាញចំពោះសំណុំរឿងរបស់ពួកគេ។ ជនរងគ្រោះមានផលប្រយោជន៍មួយក្នុងការសិក្សារៀនសូត្រពីការពិត និងការស្វែងរកការប្តឹងទាមទារផ្នែកបណ្តឹងស៊ីវិល រីឯភាគីសហព្រះរាជអាជ្ញាក៏បានទទួលនូវផលប្រយោជន៍ក្នុងការបំពេញការងាររបស់ខ្លួនបានចប់លាប់ដែរ។[45]

យោងទៅតាមមូលដ្ឋាននេះ អង្គជំនុំជម្រះតុលាការកំពូលបានយល់ព្រមធ្វើតាមនូវការចេញសេចក្តីសម្រេចរបស់អង្គជំនុំជម្រះថា គួរពន្យារពេលដំណើរការសវនាការប្រឆាំងនឹងលោកស្រី **អៀង ធីរិទ្ធ** ជាជាងការដែលបញ្ឈប់សវនាការទាំងស្រុងតែម្តង។[46]

## ផ្នែកទី ៤៖ បទបញ្ជាក្នុងការព្យាបាលផ្នែកវេជ្ជសាស្ត្រ

ដោយសារតែការពន្យារដំណើរការសវនាការ ត្រូវបានផ្អែកលើភាពចុះខ្សោយសមត្ថភាពផ្លូវចិត្តនៃជនជាប់ចោទ អង្គជំនុំជម្រះអាចត្រឹមតែអាចចាប់ផ្តើមដំណើរការជាថ្មីវិញក្នុងដំណើរការប្រឆាំងនឹងលោកស្រី **អៀង ធីរិទ្ធ** ប្រសិនបើមានការប្រសើរឡើងនៃស្ថានភាពសុខភាពរបស់គាត់ និងមានលក្ខណៈពេញលេញកាយសម្បទាសមស្របក្នុងការជំនុំជម្រះ។ ភាពសមទំនងមួយគឺថា សំណួរដែលបានផុសឡើងថាតើតុលាការមានតួនាទីបង្ខំឲ្យមានការចាត់វិធានការជាទៀតទាត់ ក្នុងគោលបំណងនៃការបង្កើនឲ្យស្ថានភាពរបស់លោកស្រី **អៀង ធីរិទ្ធ** កាន់តែមានភាពប្រសើរឡើងឬអត់។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមាត្រា ២២៣ (១១) អនុញ្ញាតឲ្យចៅក្រមស៊ើបអង្កេតម្នាក់ធ្វើការបង្ខំលើអាណត្តិ ក្នុងការព្យាបាលផ្នែកវេជ្ជសាស្ត្រទៅលើជនត្រូវចោទនៅដំណាក់កាលមុនការធ្វើសវនាការ។ ទោះជាយ៉ាងណា[47] មាត្រានេះបានសំដៅជាក់លាក់តែលើអំណាចនៃចៅក្រមស៊ើបអង្កេតតែមួយរូបតែប៉ុណ្ណោះ។ យោងតាមអង្គជំនុំជម្រះតុលាការកំពូល បានថ្លែងថា “ច្បាប់កម្ពុជា មិនបានកំណត់ពីផលប៉ះពាល់នៃកិច្ចដំណើរការនីតិវិធីទៅលើការអនុវត្តសិទ្ធិ កាតព្វកិច្ច និងសមត្ថកិច្ចក្នុងអំឡុងពេលផ្អាកកិច្ចដំណើរការនីតិវិធីឡើយ។”[48] ហេតុដូច្នេះហើយ អង្គជំនុំជម្រះចាំបាច់បំផុតត្រូវតែមើលលើយុត្តិសាស្ត្រច្បាប់អន្តរជាតិ។

---

44 Ibid, par. 28. 16.

45 Ibid, par. 28. 16.

46 The Supreme Court Chamber did not specifically address if an effective termination is legally permissible. However, its argument that a stay is the only appropriate course implies that an effective termination would be as inappropriate as an official termination of proceedings.

47 CAMBODIAN CODE OF CRIMINAL PROCEDURE, Article 223 (11): “An investigating judge may place a charged person under judicial supervision if the charged person is under investigation for an offense punishable by imprisonment. Judicial supervision has the effect of subjecting a charged person at liberty to one or more of the following obligations: … 11. to undergo a medical examination and/or treatment under the medical supervision in the hospital.”

48 SUPREME COURT DECISION, par. 17. 10.

## ក.　អំណាចនៃតុលាការក្នុងការបង្ខិតបង្ខំឲ្យមានការព្យាបាលតាមផ្នែកវេជ្ជសាស្ត្រ

អង្គជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គូស្លាវី បានចេញបញ្ជាឲ្យមានការព្យាបាលផ្នែកវេជ្ជសាស្ត្រជាច្រើនដងដល់ជនជាប់ចោទ។ ក្នុងសំណុំរឿងរបស់ *Stanišić* និងសំណុំរឿង *Simatović* អង្គជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិអតីតប្រទេសយូហ្គូស្លាវី “បានដោះលែង [Stanišić] ជាបណ្ដោះអាសន្នរួមជាមួយនឹងលក្ខខណ្ឌខ្លះៗ បូករួមទាំងការដែលត្រូវនាំជនជាប់ចោទទៅកាន់មន្ទីរពេទ្យនៅទីក្រុង **បេលហ្រ្គេដ** ដើម្បីពិនិត្យតាមដានពីស្ថានភាពសុខភាពជាប្រចាំ ហើយប្រសិនជាចាំបាច់ត្រូវការព្យាបាលដែលមានលក្ខខណ្ឌមួយត្រូវតែធ្វើឡើង...”។[49] បទបញ្ជានេះបាននាំឲ្យមានការវាយតម្លៃសន្និដ្ឋាន ក៏ដូចជាព្យាបាលផ្នែកវេជ្ជសាស្ត្រជាបន្តបន្ទាប់អូសបន្លាយពេញមួយឆ្នាំ និងការដាក់សំណើមួយចំនួនពីភាគីការពារក្តី ដើម្បីធ្វើមោឃភាពនូវការដោះលែងជាបណ្ដោះអាសន្ន ហើយចាប់ផ្ដើមការជំនុំជម្រះពីភាគីអយ្យការ ឬក៏ធ្វើការបន្តឲ្យពន្យារពេល និងធ្វើការព្យាបាលផ្នែកវេជ្ជសាស្ត្រ។ Stanišić ជាយថាហេតុហាក់ដូចជាមានសម្បទាក្នុងការជំនុំជម្រះ ហើយគឺកំពុងតែដំណើរការសវនាការរហូតដល់ពេលនេះ រួមជាមួយនឹងការកែប្រែមួយចំនួនដល់កិច្ចដំណើរការនីតិវិធី រួមបញ្ចូលទាំងការដែលគាត់អាចនឹងត្រូវតាមដានសវនាការ តាមរយៈវីដេអូរលីង (Video link) ពីទីក្រុង **បេលហ្រ្គេដ** ដើម្បីឲ្យគាត់នៅតែបន្តការព្យាបាលបាន។[50] ក្នុងសំណុំរឿងរបស់ *Kovačević* វិញ ចុងចោទត្រូវបានដោះលែងបណ្ដោះអាសន្ន និងត្រូវបានបញ្ជាឲ្យមានការគាំពារផ្នែកសុខភាពផ្លូវចិត្ត ហើយក៏ត្រូវបានផ្ដល់ឲ្យនូវការព្យាបាលតាំងពីពេលនោះមក។[51] សិទ្ធិជាក់លាក់មួយចំនួនត្រូវបានទទួលស្គាល់ក្នុងអនុសញ្ញាអន្តរជាតិមួយចំនួនស្តីពីសិទ្ធិមនុស្ស រួមមានដូចជា សិទ្ធិនៃការមានសុខមាលភាពផ្នែករូបរាងកាយ សិទ្ធិក្នុងការចូលរួមក្នុងដំណើរការនៃការការពារខ្លួន[52] និងសិទ្ធិបដិសេធមិនទទួលនូវការព្យាបាល[53] ដែលអាចនឹងផ្ដល់ទម្ងន់ប្រឆាំងនឹងអ្វីដែលធ្លាប់មានពីមុនទាំងនេះ និងបានស្នើថា លោកស្រី **អៀង ធីរិទ្ធ** គួរតែអាចធ្វើការសម្រេចចិត្តដោយខ្លួនឯងលើបញ្ហានេះ។ ទោះជាយ៉ាងណាក៏ដោយ សិទ្ធិទាំងនេះត្រូវតែបានរាប់ទុកថាជាពន្លឺនៃអង្គហេតុដែលបានចងក្រងការព្យាបាលដែលការពិតសមត្ថភាពរបស់លោកស្រី **អៀង ធីរិទ្ធ** អាចមានសភាព

---

[49] SUPREME COURT DECISION, par. 21. 13.

[50] *See* UN ICTY. “The Cases: Stanišić&Simatović (IT-03-69),” <http://www.icty.org/case/stanisic_simatovic/4>, accessed 12 November 2012.

[51] SUPREME COURT DECISION, par. 22. 13.

[52] Universal Declaration of Human Rights (10 December 1948), Article 3, “Everyone has the right to life, liberty and security of person.” ICCPR, Article 7, “…no one shall be subjected without his free consent to medical or scientific experimentation.” Article 10 (1), “All persons deprived of their liberty shall be treated with humanity and with respect for the inherent dignity of the human person.” See also Section II.A of this report.

[53] *See* U.N. Committee on Economic, Social and Cultural Rights, General Comment No. 14, “The right to the highest attainable standard of health” (November 8, 2000). par. 12; United Kingdom Mental Capacity Act, 2005; United States Supreme Court *O'Connor v. Donaldson* (1975); France, Code de la santé publique, Article L.1111.-4, par. 3. Cambodia does not appear to have similar specific protections. However, Cambodia is party to the International Covenant on Economic, Social and Cultural Rights (1966), which incorporates the right to health including the right to control one's own health and body, the right to be free from interference, and the right to be free from nonconsensual medical treatment. However, exceptions are sometimes made in all of these jurisdictions in order to provide care for people with mental illnesses.

ប្រសើរឡើងនៅក្នុងការរួមចំណែកការពារក្តីរបស់ខ្លួនផ្ទាល់ [54] និងដើម្បីធ្វើការជូនដំណឹងជាមុននូវជម្រើសផ្សេងៗសំរាប់ខ្លួនលោកស្រីផ្ទាល់ក្រោយពីពេលនោះមក។ សម្រាប់ហេតុផលមួយចំនួននៃការអនុវត្តវិញ វាជារឿងសំខាន់ណាស់ដែលតុលាការត្រូវធ្វើការពិចារណាពីភាពជោគជ័យដែលអាចប្រព្រឹត្តទៅបាន នៅពេលដែលការផ្តល់ទម្ងន់ថាតើត្រូវធ្វើការបង្ខំឲ្យមានការព្យាបាលផ្នែកវេជ្ជសាស្រ្តឬអត់។ នៅក្នុងសំណុំរឿងរបស់លោកស្រី **អៀង ធីរិទ្ធ** ក្រុមអ្នកជំនាញទាំងប្រាំរូបបានគិតថា វាហាក់ដូចជាមិនអាចទៅរួចទេដែលស្ថានភាពជំងឺរបស់លោកស្រី នឹងអាចល្អប្រសើរច្រើន ឬមិនប្រសើរសោះតែម្តង។ ទោះជាយ៉ាងណា អ្នកជំនាញការបានធ្វើបទបង្ហាញនូវវិធានការបួនយ៉ាងដែលដែលពួកគាត់គិតថាអាចនឹងធ្វើឲ្យលោកស្រី **អៀង ធីរិទ្ធ** មានស្ថានភាពប្រសើរឡើងបាន ឬក៏ត្រូវថែរក្សានូវសមត្ថភាពផ្លូវចិត្តរបស់គាត់ក្នុងកម្រិតបច្ចុប្បន្នឲ្យនៅដដែល។[55] សាស្រ្តាចារ្យ Campbell បានស្នើឲ្យមានការប្រើប្រាស់នូវថ្នាំថ្មីឈ្មោះ *Donepezil* ដែលអាចធ្វើឲ្យបង្អាក់សមត្ថភាពនៃជំងឺវង្វេងវង្វាន់ប្រមាណជាមួយភាគបីនៃអ្នកដែលប្រើថ្នាំនេះ។ ទោះជាយ៉ាងណា ការប្រសើរឡើងអាចនឹង "មានកម្រិតត្រឹមតែតិចតួចតែប៉ុណ្ណោះ"។[56] ម្យ៉ាងវិញទៀត *Donepezil* បច្ចុប្បន្ននេះគឺមិនអាចរកបាននៅក្នុងប្រទេសកម្ពុជាទេ ហើយដែលតម្រូវឲ្យមានការរក្សាទុកក្នុងសីតុណ្ហភាពមួយដ៏ត្រឹមត្រូវ ក៏ដូចជាទាមទារឲ្យមានការប្រយ័ត្នប្រយែងក្នុងការគ្រប់គ្រងផងដែរ។ ហេតុដូច្នេះ វាអាចនឹងមិនអាចធ្វើទៅកើតទេក្នុងការគ្រប់គ្រងថែរក្សាថ្នាំនេះនៅក្នុងប្រទេសកម្ពុជា ដើម្បីឲ្យឆ្លើយតបទៅនឹងស្ថានភាពជំងឺដូចដែលលោកស្រី **អៀង ធីរិទ្ធ** កំពុងមានបច្ចុប្បន្ននេះ។[57]

អ្នកជំនាញការផ្នែកវិកលចរិកទាំងបួនរូប បានស្នើសុំនូវវិធានការដែលមានភាពស្មុគស្មាញតិចតួចក្នុងករណីនេះ។ ពួកគាត់បានស្នើថា ឲ្យលោកស្រីរស់ក្នុងបរិយាកាសសមរម្យ ការធ្វើលំហាត់ប្រាណដោយមានការវាយតម្លៃពីអ្នកឯកទេសផ្នែកសេរីរៈ ក៏ដូចជាការហ្វឹកហ្វឺនផ្នែកផ្លូវចិត្ត បូករួមជាមួយការព្យាបាលដោយប្រើប្រាស់វិធីសាស្រ្តផ្អែកតាមស្ថានភាពវេជ្ជសាស្រ្ត ដែលបាននឹងកំពុងប្រើដើម្បីថែទាំ ឬក៏ធ្វើឲ្យប្រសើរឡើងនូវមុខនាទីនៃការដឹងរបស់លោកស្រី **អៀង ធីរិទ្ធ**។[58] លោកសាស្រ្តាចារ្យ **Campbell** បានកត់សម្គាល់ថា "យើងមិនអាចកំណត់បានថា ជនជាប់ចោទមិនអាចចូលរួមក្នុងការការពារក្តីរបស់ខ្លួននោះទេ ដរាបណាយើងមិនទាន់បានរិះរកគ្រប់លទ្ធភាព និងព្យាយាមគ្រប់វិធាន

---

[54] Supreme Court Decision, par. 35, 37.18, 19.

[55] First, Professor Campbell tried a careful reduction of her psychotropic medications to try to gain a slight improvement in her condition. However, after the reduction of those drugs, Professor Campbell reexamined the accused and found her condition the same. (Follow-Up Report of the Geriatrician.)

[56] Ibid, par. 8(ii), cited in Trial Chamber Decision, par. 37. 14.

[57] Trial Chamber Decision, par. 53. 19.

[58] The Psychiatrists stated that the following may be beneficial to the accused: "[C]onsistent and stable staffing; retaining a familiar environment; flexibility to accommodate her fluctuating abilities; physical exercise, with assessment and advice from a physiotherapist when needed; and support for participation in activities she enjoys. In addition, a structured cognitive stimulation programme may be helpful (but needs to be undertaken with those who are trained and supervised). Furthermore, the treatment of her knee and back pain and the regular monitoring of her physical health would be important to maintain. The continued treatment of co-existent medical conditions will improve her prognosis. We note that there are no occupational therapists currently in Cambodia, but if there were, an assessment of her activities of daily living would be helpful and advice on any environmental modifications to her living conditions could be sought." (Psychiatric Experts' Report, cited in Supreme Court Decision, par. 36. 19.

ការក្នុងការសាកល្បង និងធ្វើឲ្យប្រសើរឡើងនោះ"។[59] ទោះជាយ៉ាងណា អ្នកជំនាញទាំងនេះបានបញ្ជាក់ជាទូទៅថា នៅពេលកំពុងប្រើប្រាស់ថ្នាំព្យាបាល ការធ្វើការហ្វឹកហាត់លើផ្លូវចិត្ត និងវិធីថែទាំសមរម្យផ្សេងៗទៀតអាចនឹងមានសភាពយឺតយ៉ាវ ឬនាំឲ្យកាន់តែយ៉ាប់យ៉ឺនឡើងនៃសមត្ថភាពផ្លូវចិត្តរបស់គាត់ ដែលពួកគាត់មិនមានសមត្ថភាពក្នុងការធ្វើឲ្យប្រសើរឡើងបានទេ។[60]

## ខ. សេចក្តីសម្រេចយោងតាមការបញ្ជាមួយនៃការព្យាបាលផ្នែកវេជ្ជសាស្រ្ត

អង្គជំនុំជម្រះបានបំបែកលើបញ្ហាដែលថាតើអាច ឬមិនគួរចេញបញ្ជាឲ្យមានការព្យាបាលផ្នែកវេជ្ជសាស្រ្តដល់ជនជាប់ចោទ។ ក្រុមចៅក្រមជាតិ បានអនុគ្រោះក្នុងការចេញបញ្ជាឲ្យមានការព្យាបាលផ្នែកវេជ្ជសាស្រ្ត ដោយឡែកចៅក្រមអន្តរជាតិបានរកឃើញថា "ពុំមានមូលដ្ឋានគតិយុត្តិណាមួយ ដែលតម្រូវបង្គាប់ឲ្យលោកស្រី **អៀង ធីរិទ្ធ** ចូលសំរាកក្នុងមន្ទីរពេទ្យនោះទេ" ដោយបានលើកឡើងថា សំណុំរឿងរបស់លោកស្រីត្រូវបានផ្អាក និងវាហាក់ដូចជាមិនអាចទេដែលដំណើរការសវនាការលើលោកស្រីអាចបន្តទៅបាន។[61]

សហចៅក្រមជាតិ បានពឹងផ្អែកយ៉ាងធ្ងន់ទៅលើក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា២២៣ (១១) ដែលបានថ្លែងថា "ចៅក្រមស៊ើបសួរ អាចដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា..." ក្រោមកាលៈទេសៈជាក់លាក់ដែលបានដកស្រង់ និងដែលការថែទាំគ្រប់គ្រងបានចែងថា "ការត្រួតពិនិត្យតាមផ្លូវតុលាការនេះ មានអានុភាពបង្គាប់ជនត្រូវចោទដែលនៅក្រៅឃុំឲ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចតទៅ...ត្រូវប្រគល់ខ្លួនឲ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុ ដាក់ឲ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ"។[62] ទោះជាយ៉ាងនេះក្តី ក្រុមចៅក្រមអន្តរជាតិបានតវ៉ាថា មាត្រានេះអាចមាន ឬអាចប្រើបានតែក្នុងវិធានការមុនដំណាក់កាលសវនាការតែប៉ុណ្ណោះ ពោលគឺថាក្នុងការមើលឃើញរបស់ពួកគាត់ចំពោះបញ្ហានេះ គឺមានភាពខុសគ្នាទាំងស្រុងព្រោះចុងចោទត្រូវបានចោទប្រកាន់រួចហើយ និងត្រូវបានរកឃើញថាមិនមានសម្បទាគ្រប់គ្រាន់ក្នុងការជំនុំជម្រះរួចហើយដែរ ហើយដែលដំណើរការនីតិវិធីត្រូវបានផ្អាកដោយគ្មាន "មូលហេតុសមស្របថា នឹងមានការជំនុំជម្រះក្តីលើរូបគាត់ឡើងវិញបាននោះ"។[63]

ក្រុមចៅក្រមជាតិ ក៏បានទាញនូវសំណុំរឿងរបស់ *Kovačević* ពី ICTY ដើម្បីគាំទ្រដល់ការបង្ខំឲ្យរួមគ្នាចេញបញ្ជាព្យាបាលផ្នែកវេជ្ជសាស្រ្តដល់ជនជាប់ចោទរូបនេះ។ ទោះជាយ៉ាងណាក្តី ក្រុមចៅក្រមអន្តរជាតិមានអារម្មណ៍ថាករណីនេះ មិនមានការពាក់ព័ន្ធនឹងរឿងពីមុនៗទេ ព្រោះសំណុំរឿងរបស់ *Kovačević* គឺថាភាគីទាំងពីរបានយល់ព្រមក្នុងការព្យាបាលផ្នែកវេជ្ជសាស្រ្ត។[64] ក្នុងសំណុំរឿង

---

59 SUPREME COURT DECISION, par. 35, 18, citing Transcript 30 August 2011, p. 92, lines 16-19.
60 TRIAL CHAMBER DECISION, par. 70-2. 25-26.
61 Ibid, par. 74. 26.
62 CAMBODIAN CODE OF CRIMINAL PROCEDURE, Article 223 (11).
63 TRIAL CHAMBER DECISION, par. 74. 26.
64 Ibid, par. 75. 27.

របស់លោកស្រី **អៀង ធីរិទ្ធ** ភាគីការពារក្ដីមិនបានដាក់សំណើណាមួយ ហើយការពិតថែមទាំងបានជំទាស់ក្នុងបញ្ជាឲ្យមានការព្យាបាលផ្នែកវេជ្ជសាស្ត្រទៀតផង។[65] ក្រុមចៅក្រមអន្តរជាតិ បានផ្ទេរទម្ងន់ជាពិសេស(ដោយឡែក) លើរបបគំហើញពីអ្នកជំនាញការផ្នែកវេជ្ជសាស្ត្រទាំងនេះថា ស្ថានភាពរបស់លោកស្រី **អៀង ធីរិទ្ធ** គឺហាក់ដូចជាមិនអាចនឹងប្រសើរឡើងបានទេ។ របកគំហើញនេះបានទុកចន្លោះសម្រាប់លទ្ធផលផ្សេងគ្នា ប្រសិនបើអង្គហេតុត្រូវបានបកស្រាយដើម្បីបញ្ចប់ពីការជជែកលើស្ថានភាពរបស់លោកស្រី **អៀង ធីរិទ្ធ** ដែលថាអាចនឹងមានភាពប្រសើរឡើងនោះ។ សហព្រះរាជអាជ្ញា បានសម្ដែងមតិផ្ដោតលើភាពត្រឹមត្រូវនៃបញ្ហានេះ។ ក្រុមសហព្រះរាជអាជ្ញាបានគិតថាអាចនឹងទៅរួច ដែលលោកស្រី **អៀង ធីរិទ្ធ** អាចនឹងជាសះស្បើយពេញលេញ ថែមទាំងមានសម្បទាគ្រប់គ្រាន់ក្នុងការជំនុំជម្រះ ហេតុដូច្នេះហើយ វិធានការទាំងអស់គួរតែត្រូវបានព្យាយាមសាកល្បងប្រើប្រាស់ដើម្បីជួយឲ្យស្ថានភាពរបស់ជនជាប់ចោទរូបនេះអាចជាសះស្បើយបាន។

ទីបំផុត អង្គជំនុំជម្រះតុលាការកំពូលបានយល់ព្រមតាមសំណើលើកឡើងជាមួយ សហព្រះរាជអាជ្ញាដោយបានសន្និដ្ឋានថា វាជារឿងសមរម្យក្នុងការបញ្ជាឲ្យមានការព្យាបាលផ្នែកវេជ្ជសាស្ត្រដល់ជនជាប់ចោទ ពីព្រោះតុលាការមានតួនាទីមួយក្នុងការប្រើឲ្យអស់លទ្ធភាពតាមដែលអាចធ្វើទៅបានដើម្បីឲ្យចុងចោទមានសម្បទាគ្រប់គ្រាន់ក្នុងការជំនុំជម្រះ មុនពេលដែលចុងចោទត្រូវបានដោះលែង។[66] អង្គជំនុំជម្រះ បានកត់សម្គាល់ថាអ្នកជំនាញការផ្នែកវេជ្ជសាស្ត្របានធ្វើបទបង្ហាញនូវភាពដែលអាចធ្វើទៅបានមួយ តែទោះជាយ៉ាងណា មានត្រឹមកម្រិតតិចតួចបំផុតដែលស្ថានភាពរបស់ជនជាប់ចោទអាចនឹងធ្វើឲ្យមានភាពប្រសើរឡើង។ ដូចដែលបានលើកឡើងខាងលើនេះ តុលាការអាចនឹងចេញបញ្ជាឲ្យលោកស្រី **អៀង ធីរិទ្ធ** ទទួលនូវអនុសាសន៍ណែនាំក្នុងការព្យាបាល[67] ក្រោមការមើលការខុសត្រូវពីអង្គជំនុំជម្រះ។[68]

---

[65] IengThirith Defense. "Response by Defense for Madame IengThirith to Co-Prosecutors Appeal Against the Trial Chamber's Decision of 17 November 2011" (28 November 2011). E138/1/5, [hereinafter, **DEFENSE RESPONSE**]. With reference to Internal Rule 63(3), the Defense stated, "there is no condition which provides for compulsory hospitalization for an accused to obtain medical treatment." (par. 23) "Therefore, it is submitted that the Respondent should be released unconditionally." (par. 31)

[66] SUPREME COURT DECISION, par. 19-20, 25, 28. "Once a person has been charged, international criminal courts have gone to great lengths to ensure that every possibility to prosecute the accused is exhausted, including where the accused suffers from a serious medical condition" (par. 19. 11). "During a stay of criminal proceedings, measures of compulsion can be ordered against an accused with a serious medical condition" (par. 20. 12). In *Stanišić*,*Kovačević*,and *Tadić*, the accused were all required to submit to medical treatment as a part of their provisional release. The Supreme Court Chamber found these precedents indicate that mandatory treatment that was instrumental for the goal of resuming proceedings was permissible. (par. 25. 14)

[67] "The Supreme Court Chamber holds that, considering the interest of justice in trying the accused, upon a finding of unfitness, remedial action must be undertaken in the light of a possibility, even slight, of a meaningful improvement." Ibid, par. 29. 17. The Chamber noted however that this treatment was "not based on an urgent medical need but on the need to pursue the possibility of improving her mental condition" and to make her fit for trial. As such, "the present case is distinguishable from the international case law…" (Ibid, par. 42. 21).

[68] "Once seized with the Closing Order, the Trial Chamber alone has the authority to establish and implement such a mechanism, as the Trial Chamber alone has the jurisdiction over the Accused." (Ibid, par. 29. 16.) This is in response to the Trial Chamber's order for the OCP to monitor the accused. The OCP appealed that no statute supported the OCP responsibility to oversee treatment or assessment of the accused, and therefore it was outside of its powers. As such, the OCP felt it could not implement this order and would therefore never be able to reassess IengThirith and be in a position to ask for the Chamber to resume trial. The OCP felt, therefore, that this order was an effective termination of proceedings. (IMMEDIATE APPEAL, par. 5.) The Defense disagreed, saying the OCP has "the inherent ability to ask the Trial Chamber to reassess the accused and recommence the trial at any time." (Defense Response, par. 17, cited in SUPREME COURT DECISION, par. 14. 9.)

## ផ្នែកទី ៥៖ ការបន្តឃុំឃាំង ឬដោះលែង

នៅពេលដែលអង្គជំនុំជម្រះតុលាការកំពូល បានចេញបញ្ជាឲ្យមានការព្យាបាលផ្នែកវេជ្ជសាស្ត្រដល់លោកស្រី **អៀង ធីរិទ្ធ** អង្គជំនុំជម្រះក៏បានលើកឡើងថាតើវាអាច ឬមិនគួរបន្តឃុំឃាំងលោកស្រី **អៀង ធីរិទ្ធ** ឬត្រូវដោះលែងបណ្ដោះអាសន្នដើម្បីទទួលការព្យាបាលផ្នែកវេជ្ជសាស្ត្រ។

### ក. មូលដ្ឋានផ្លូវច្បាប់ស្ដីពីការបន្តការដាក់ឃុំឃាំង

ច្បាប់អន្តរជាតិ និងច្បាប់ដែលមានពីមុនៗមក គាំទ្រនូវសិទ្ធិជាមូលដ្ឋានគ្រឹះដើម្បីបានសេរីភាព។[69] កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធនយោបាយមាត្រា ៩ (១) ថ្លែងថា "បុគ្គលគ្រប់រូបមានសិទ្ធិក្នុងការទទួលបាននូវសេរីភាព និងសុវត្ថិភាពបុគ្គល។ មិនមានជនណាម្នាក់ត្រូវបានក្លាយជាកម្មវត្ថុក្នុងការចាប់ខ្លួន ឬឃុំឃាំងទុកដោយបំពានឡើយ។ មិនមានជនណាម្នាក់ត្រូវបានដកហូតនូវសិទ្ធិសេរីភាពបុគ្គលរបស់ខ្លួន លើកលែងតែមូលដ្ឋាននៃការចាប់ខ្លួននោះ ហើយនិងនីតិវិធីដែលបានអនុញ្ញាតត្រូវបានបង្កើតឡើងដោយច្បាប់"។[70] ហេតុដូច្នេះ មានការសន្មតទុកជាមុនក្នុងការអនុគ្រោះដល់សេរីភាពបុគ្គល។

ម្យ៉ាងវិញទៀត ទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិអនុគ្រោះដល់ការសន្មតទុកជាមុនមួយនៃការធានាជាប្រាក់ ជាជាងការឃុំឃាំងសម្រាប់ការប្រឈមមុខនឹងបទចោទប្រកាន់ផ្នែកព្រហ្មទណ្ឌ។ មាត្រា៣០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាថ្លែងថា "...ជនជាប់ចោទចូលបង្ហាញខ្លួនដោយសេរី លើកលែងតែចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរបានសម្រេចឲ្យឃុំខ្លួនជាបណ្ដោះអាសន្ន"។[71] វិធានផ្ទៃក្នុងនៃ **អ.វ.ត.ក** ៨២(១) ថ្លែងថា "ជនជាប់ចោទត្រូវមានសេរីភាពរហូតដល់ពេលចូលមកបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង លើកលែងតែមានការបង្គាប់ឲ្យមានការឃុំខ្លួនបណ្ដោះអាសន្ន..."។[72] អង្គជំនុំជម្រះតុលាការកំពូលនៃ **អ.វ.ត.ក** បានចេញសេចក្ដីសម្រេចថា "ការបកស្រាយត្រូវតែផ្ដល់ប្រយោជន៍ដល់ជនជាប់ចោទ ហើយសេរីភាពគឺជាវិធាន រីឯការឃុំឃាំងគឺជាករណីពិសេស"។[73]

យ៉ាងណាក៏ដោយ បើទោះជាមានការសន្មតទុកជាមុនយ៉ាងដូចនេះមែន វាអាចនឹងត្រូវបានចាត់ទុកដាក់ថាជាការសមរម្យក្នុងការឃុំឃាំងជនជាប់ចោទម្នាក់ក្នុងហេតុផលមួយចំនួន រួមបញ្ចូលទាំងការធានាការបង្ហាញខ្លួនចុងចោទក្នុងតុលាការ ការពារនូវការគំរាមកំហែងពីសង្គមតាមដែលអាចធ្វើទៅបាន និងធ្វើការការពារនូវកំហឹងពីសហគមន៍ទាក់ទងនឹងទង្វើព្រហ្មទណ្ឌទាំងឡាយដូចដែលបានចែងតាមដែលអាចធ្វើទៅបាន។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតឲ្យ

---

[69] *See also* TRIAL CHAMBER DECISION, par. 80. 29.
[70] ICCPR, Article 9 (1).
[71] CAMBODIAN CODE OF CRIMINAL PROCEDURE, Article 305.
[72] Internal Rule 82 (1).
[73] "The interpretation most favorable to the Accused must be preferred, and liberty is considered the norm and detention is an extraordinary measure." SUPREME COURT DECISION, par. 9. 5-6.

មានការឃុំឃាំងមុនដំណាក់កាលសវនាការ ក្រោមហេតុផលមួយចំនួនទាំងនេះ។ មាត្រា២២៣ រកឃើញថាការឃុំខ្លួនបណ្ដោះអាសន្ន អាចនឹងសមរម្យទៅបាននៅក្នុងការធានាឲ្យមានវត្តមានរបស់ជនជាប់ចោទ ចេញវិភាគទាននូវសន្តិសុខរបស់លោកស្រីពីសាធារណជន និងផ្ដល់នូវឱសថព្យាបាលសមស្របដល់គាត់ផងដែរ។[74] ក្រមព្រហ្មទណ្ឌកម្ពុជា ដែលត្រូវបានអនុម័តដោយសភាជាតិកាលពីខែមិថុនា ឆ្នាំ២០០៧ និងបានយល់ព្រមផងដែរពីព្រឹទ្ធសភាកាលពីខែកក្កដា ឆ្នាំ២០០៧[75] ក៏បានអនុញ្ញាតផងដែរនូវការឃុំឃាំងជាបណ្ដោះអាសន្នចំពោះបទឧក្រិដ្ឋ ដែលបានប្រកាសដោយផ្ដោតជាក់លាក់លើសេចក្ដីប្រកាសទាំងនោះ រួមមានការបានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម ការសម្លាប់រង្គាល ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។[76] ព្រោះហេតុដូចនោះ វិធានផ្ទៃក្នុងនៃ **អ.វ.ត.ក** បានបញ្ជាថា គ្រប់វិធានការសវនាការទាំងអស់ "ជនជាប់ចោទត្រូវស្ថិតក្នុងឃុំដដែល រហូតដល់ពេលសាលក្រមនៃអង្គជំនុំជម្រះសាលាដំបូងត្រូវបានសម្រេចសេចក្ដី..."។[77]

ការអនុវត្តនៅក្នុងតុលាការអន្តរជាតិផ្សេងៗទៀត ក៏មានភាពប្រហាក់ប្រហែលគ្នានឹងយុត្តិសាស្ត្ររបស់**អ.វ.ត.ក** ដែរ។ តុលាការព្រហ្មទណ្ឌអន្តរជាតិអតីតប្រទេសយូហ្គូស្លាវី ICTY ត្រូវបានឃុំឃាំងយ៉ាងជាប់លាប់ មានតែការដោះលែងចុងចោទជាបណ្ដោះអាសន្នតែប៉ុណ្ណោះ ដើម្បីធានានូវការបង្ហាញខ្លួនរបស់ពួកគេក្នុងតុលាការ ការការពារពីបរិយាកាសសង្គម និងសម្របសម្រួលដល់ការព្យាបាលផ្នែកវេជ្ជសាស្ត្រ។ នៅក្នុងរដ្ឋអាជ្ញាតទល់នឹងសំណុំរឿង *Kovačević* អង្គជំនុំជម្រះបានចេញបញ្ជាឲ្យមានការឃុំខ្លួនបណ្ដោះអាសន្ន ដើម្បីសម្រួលលើការពាក់ព័ន្ធនៃការព្យាបាលឈានទៅដល់ការជាសះស្បើយរបស់ជនជាប់ចោទ ក៏ដូចជាការព្យាយាមធ្វើយ៉ាងណាឲ្យជនជាប់ចោទមានសម្បទាគ្រប់គ្រាន់ដើម្បីជំនុំជម្រះ។

ក្នុងសំណុំរឿង *Djukić*, *Stanišić* និងសំណុំរឿង *Tadić* ចុងចោទទាំងពីរត្រូវបានដោះលែងជាបណ្ដោះអាសន្នដោយសារស្ថានភាពសុខភាព ទាំងមូលដ្ឋានផ្នែកមនុស្សធម៌នៅក្នុងការថែទាំជីវិតចុងក្រោយ ឬសម្របសម្រួលឲ្យមានការព្យាបាលជាដើម។[78] សំណុំរឿងទាំងនេះ ហាក់ដូចជាបានរៀបចំនូវអ្វីៗដែលមានពីមុនយ៉ាងច្បាស់លាស់នៅតុលាការ ICTY ស្ដីពីការឃុំខ្លួន ឬត្រឹមតែការដោះលែងបណ្ដោះអាសន្នតែប៉ុណ្ណោះ ដែលជាការរារាំងដល់ការដោះលែងដោយគ្មានលក្ខខណ្ឌ។ ទោះជាយ៉ាងណាក្ដី ភាគីការពារក្ដីបានតវ៉ាថា សំណុំរឿងទាំងនេះមិនបានចង្អុលបង្ហាញថាការបន្តឃាត់ខ្លួន ឬបន្ត

---

[74] CAMBODIAN CODE OF CRIMINAL PROCEDURE, Article 223(4), (5), (11). This citation was challenged by the international Trial Chamber Judges, see section IV.C, par. 1 of this paper.

[75] Criminal Procedure Code of the Kingdom of Cambodia. 2. Available at <http://www.oecd.org/site/anti-corruptioninitiative/46814242.pdf>, accessed 12 November 2012.

[76] CAMBODIAN CODE OF CRIMINAL PROCEDURE, Article 210, "In case of crimes against humanity, genocide or war crimes, provisional detention shall not exceed one year for each of these offenses. However, when this time period ends the investigating judge may extend a provisional detention for another year by an order with a proper and express statement of reasons. The extension can only be made twice." Article 205, "Provisional detention may be ordered when it is necessary to: 1. stop the offense or prevent the offense from happening again; 2. Prevent any harassment of witnesses or victims or prevent any collusion between the charged person and accomplices; 3. preserve evidence or exhibits; 4. guarantee the presence of the charged person during the proceedings against him; 5. protect the security of the charged person; 6. preserve public order from any trouble cause by the offense."

[77] Internal Rule 82 (1).

[78] *See* III, paragraphs 6-8 of this report.

ដាក់ឃុំឃាំងគឺជាបទដ្ឋានទេ នៅពេលដែលជនជាប់ចោទត្រូវបានរកឃើញថាមិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។ ហើយថាផ្ទុយទៅវិញ ស្ថានភាពនីមួយៗគួរតែត្រូវបានវាយតម្លៃទៅតាមករណីនីមួយៗ ។[79]

តុលាការព្រហ្មទណ្ឌអន្តរជាតិ តែងតែបានរក្សាទុកជនជាប់ចោទក្រោមការឃុំឃាំងរបស់ខ្លួន នៅពេលដែលពួកគេត្រូវបានចាប់ខ្លួន ពោលគឺទាញការព្រួយបារម្ភអំពីការធានាឲ្យមានការបង្ហាញខ្លួននៅក្នុងតុលាការ។ ក្នុងរដ្ឋអាជ្ញាទល់នឹងសំណុំរឿង *Lubanga* អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចនូវការពន្យារពេលដោយមិនកំណត់ព្រំដែននៃដំណើរការសវនាការ ព្រោះតែភាពអាចកើតមានបាននៃការរំលោភបំពានផ្សេងៗនៃសិទ្ធិក្នុងការជំនុំជម្រះ។ អង្គជំនុំជម្រះ បានរកឃើញថាកាលនោះនៅពេលដែល "មិនមានការរំពឹងទុកណាមួយដែលថា សិទ្ធិនៅក្នុងការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌អាចនឹងត្រូវកើតមានឡើង"។ ទោះជាយ៉ាងណាក្តី តុលាការបានរកឃើញថា បើទោះជាមានហេតុផលក្នុងការពន្យារយ៉ាងដូចនេះក្តី ក៏តុលាការមិនចាំបាច់ហាមឃាត់មិនឲ្យអនុវត្តយុត្តាធិការជាអចិន្ត្រៃយ៍ដែលទាក់ទងនឹងបុគ្គលទេ។ [80] អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិបានលើកហេតុផលថា វាត្រូវការនូវការរក្សាទុកជនជាប់ចោទឲ្យស្ថិតក្រោមការឃុំឃាំងដើម្បីធានាថាគាត់នឹងអាចបង្ហាញខ្លួនបាន ប្រសិនបើសវនាការចាប់ផ្តើមបើកសាជាថ្មី។ តុលាការសិទ្ធិមនុស្សអឺរ៉ុបថ្លែងថា ការបន្តដាក់ការឃុំខ្លួនអាចបង្ហាញថាត្រឹមត្រូវតែនៅក្នុងករណីដែលមានការបង្ហាញជាក់លាក់ដើម្បីបង្ហាញថាអាចមានហានិភ័យក្នុងការរត់គេចខ្លួន ឬការនាំឲ្យខាតប្រយោជន៍ដល់ជនជាប់ចោទ ឬបុគ្គលដទៃផ្សេងៗទៀត។[81]

## ខ. កង្វល់នៃការអនុវត្ត និងការព្យាបាលផ្នែកវេជ្ជសាស្ត្រដែលប្រសើរបំផុត

ការដែលបានផ្តល់នូវស្ថានភាពជាក់ស្តែងរបស់ជនជាប់ចោទ **អៀង ធីរិទ្ធ** ជាពិសេសការបាត់បង់នូវការចងចាំរបស់គាត់ ក៏ដូចជាការលំបាកក្នុងការផ្ចង់អារម្មណ៍ អង្គជំនុំជម្រះនៃតុលាការកំពូលបានគូសបញ្ជាក់នូវការព្រួយបារម្ភអំពីសមត្ថភាពរបស់ជនជាប់ចោទរូបនេះ ក្នុងការបង្ហាញខ្លួនក្នុងបន្ទប់សវនាការ ព្រមទាំងការចូលរួមនូវកិច្ចប្រជុំពាក់ព័ន្ធមួយចំនួនដោយមិនមានការក្រើនរំលឹក និងតាមការពារក្នុងពេលដែលគាត់ត្រូវនិយាយស្តីក្នុងពេលប្រជុំទាំងនោះ។[82]

តុលាការ បានផ្ទេរនូវការចាប់អារម្មណ៍នៅក្នុងការធ្វើឲ្យសមត្ថភាពផ្នែកផ្លូវចិត្តរបស់លោកស្រី **អៀង ធីរិទ្ធ** បានប្រសើរឡើង ក៏ដូចជាភាពប្រសើរឡើងមួយចំនួនទៀតដែលធ្វើឲ្យគាត់មានសម្បទាសមរម្យក្នុងការជំនុំជម្រះ។ អ្នកជំនាញការផ្នែកវេជ្ជសាស្ត្រទាំងអស់បានលើកឡើងថា ការដោះលែង

---

[79] SUPREME COURT DECISION, par. 12.7-8, citing Response to Immediate Appeal, par. 24-5.

[80] The Court retained the accused in custody because of the "conditional character" of the stay. *Prosecutor v. Lubanga*. "Judgment on the appeal of the Prosecutor against the decision of Trial Chamber I entitled 'Decision on the release of Thomas LubangaDyilo'" Appeals Chamber 21 October 2008, par. 37. Cited in SUPREME COURT DECISION, par. 24. 14.

[81] SUPREME COURT DECISION, par. 44. 21.

[82] The Chamber stated, the "present deficiencies with the Accused's memory [created]… a greater risk that she may render herself unavailable for trial…" Ibid, par. 41. 21. See also, GERIATRIC EXPERT REPORT, par. 13. 8.

លោកស្រីឲ្យទៅសំរាក និងទទួលបរិយាកាសជុំវិញផ្ទះកំណើតប្រហែលជាអាចជួយធ្វើឲ្យស្ថានភាពសុខភាពផ្លូវចិត្តរបស់លោកស្រីកាន់តែប្រសើរឡើង។ ទោះជាយ៉ាងណា ការឃុំឃាំងមួយ ដែលគួរតែបានធ្វើឡើងរវាងតុលាការ និងអ្នកចុះកិច្ចសន្យាវិជ្ជាជីវៈមួយចំនួនអាចនឹងធ្វើការសង្កេតឃ្លាំមើលបានល្អប្រសើរទាំងការព្យាបាល និងភាពវិវឌ្ឍន៍នៃស្ថានភាពសុខភាពរបស់លោកស្រី។ អង្គជំនុំជម្រះបានរកឃើញថា វិធានការដែលមានភាពមិនសូវរឹតត្បិត ដូចជាការដោះលែងបណ្ដោះអាសន្នអាចនឹងមានប្រសិទ្ធភាពតិចតួចក្នុងការសម្រេចគោលបំណងនៃការធ្វើកិច្ចប្រតិបត្តិការព្យាបាល និងធ្វើក្នុងកម្រិតខ្ពស់បំផុតដើម្បីព្យាយាមធ្វើឲ្យជនជាប់ចោទមានសម្បទាសមរម្យក្នុងការជំនុំជម្រះ។[83] លើសពីនេះទៀត ក្រុមអ្នកជំនាញបានវិនិច្ឆ័យថា ការរស់នៅក្នុងបន្ទប់ឃុំឃាំង មិនមែនធ្វើឲ្យប៉ះពាល់ដល់ការខូចប្រយោជន៍ដល់សភាពផ្លូវចិត្តរបស់លោកស្រីទេ។ អង្គជំនុំជម្រះនៃតុលាការ ICTY បានប្រឈមមុខនឹងបញ្ហាស្រដៀងគ្នានេះដែរក្នុងរដ្ឋអាជ្ញាទល់នឹងសំណុំរឿង *Kovačević*។ ក្នុងសំណុំរឿងនោះ អង្គជំនុំជម្រះបានថ្លែងថា ការដោះលែងបណ្ដោះអាសន្នអាចជាហេតុផលសមរម្យមួយក្នុងការសម្របសម្រួលដល់ការថែទាំផ្នែកវេជ្ជសាស្ត្រ របូតទាល់តែអាជ្ញាធរប្រទេស **ស៊ីប៊ីយ៉ា** ព្រមទទួលធ្វើការអង្កេតឃ្លាំមើលដ៏សមរម្យមួយ បូករួមទាំងការចាត់វិធានការការពារផ្នែកសន្តិសុខជាដើមដល់ជនជាប់ចោទ។[84]

## គ. សេចក្ដីសម្រេច

អង្គជំនុំជម្រះនៃតុលាការកំពូលបានតវ៉ាថា វិធានការមួយចំនួនបានផ្ដោតសំខាន់ដើម្បីមិនឲ្យមានការភ័យខ្លាច ឬព្រួយបារម្ភណាមួយក្នុងការបង្ហាញខ្លួនរបស់ជនជាប់ចោទក្នុងសវនាការ ឬធ្វើការប៉ុនប៉ង ក្នុងការសម្របសម្រួលការចាប់ផ្ដើមដំណើរការសវនាការជាថ្មីឡើងវិញ មិនអាចនឹងទៅរួចបានទេ។[85] ហេតុដូច្នេះ អង្គជំនុំជម្រះបានរកឃើញថា ការបន្តឃុំខ្លួនអាចនឹងមានការអនុញ្ញាតជាដំបូងទីក្នុងការធានានូវការមានវត្តមានរបស់ជនជាប់ចោទក្នុងសវនាការ ឯទីពីរគឺថាដើម្បីធានានូវការព្យាបាលយ៉ាងប្រសើរបំផុតដែលអាចឈានដល់ការជាសះស្បើយទាំងស្រុង និងអាចចូលសវនាការបាន។[86] អង្គជំនុំជម្រះបានធ្វើការសម្រេចចិត្តក្នុងការរក្សាទុកលោកស្រី **អៀង ធីរិទ្ធ** ឲ្យនៅក្នុងមន្ទីរឃុំឃាំងរបស់ **អ.វ.ត.ក** ឬរក្សាទុកក្នុងកន្លែង ឃុំខ្លួនសមរម្យណាផ្សេងទៀត ជាទីដែលត្រូវបានមើលឃើញថាមានភាពល្អប្រសើរក្នុងការផ្ដល់ការថែទាំសុខភាពរបស់លោកស្រី។[87] អង្គជំនុំជម្រះបានចេញបញ្ជាឲ្យលោកស្រីដាក់នូវសំណើស្ដីពីការព្យាបាលផ្នែកវេជ្ជសាស្ត្រដូចដែលបានចង្អុលបង្ហាញដោយអ្នកជំនាញការផ្នែកវេជ្ជសាស្ត្រ និងធ្វើការបន្តការពិនិត្យតាមដានបញ្ហាផ្សេងៗទៀត រួមមានការ

---

83 Ibid, par. 45. 22.

84 *Prosecutor v. Kovačević*. IT-01-42/2-1. ICTY Trial Chamber I."Decision on Provisional Release" (2 June 2004).

85 SUPREME COURT DECISION, par. 25. 14. Supported by several national jurisdictions, including those of Sri Lanka, Italy, South Korea, Zambia, Poland (SUPREME COURT DECISION, footnote 84. 15.).

86 Ibid, par. 48. 23.

87 The Supreme Court "established that the stay of proceedings ordered by the Trial Chamber is not a permanent disposition of the proceedings and that restrictive measures, including detention, are not inherently precluded during the stay, and … concluded that the ECCC is obliged to exhaust all measures available to it which may help improve the Accused to be become fit to stand trial…" (Ibid, par. 38. 19.)

រវើរវាយ និងសុខភាពរាងកាយក្រោយ៦ខែនៃការព្យាបាលចុងក្រោយ។

អង្គជំនុំជម្រះ មិនបានដោះស្រាយនូវការជំទាស់តវ៉ាពីសំណាក់ចៅក្រមអន្តរជាតិ ដែលថាវិធានការ ទាំងនេះអាចនឹងអនុញ្ញាតទៅបានជាមួយនឹងកិច្ចព្រមព្រៀងជាមួយជនជាប់ចោទ តាមរយៈមេធាវីប្រឹក្សាក្តីរបស់ជនជាប់ចោទតែប៉ុណ្ណោះ បើប្រៀបធៀបនឹងសំណុំរឿងរបស់ *Kovačević* ។

## ឃ. អានុភាពពាក់ព័ន្ធបន្ថែម៖ ការបន្តការឃុំខ្លួន ប្រសិនបើស្ថានភាពលោកស្រី អៀង ធីរិទ្ធ មិនអាចប្រសើរឡើង

អង្គជំនុំជម្រះ បានសម្រេចថាស្ថានភាពជនជាប់ចោទ **អៀង ធីរិទ្ធ** នៅតែមានឱកាសអាចប្រសើរឡើងបាន។ ទោះជាយ៉ាងណា ភាគីទាំងអស់បានចងចាំថា មានតែឱកាសតិចតួចបំផុតអ្នកជំងឺ Alzheimer អាចនឹងមានស្ថានភាពប្រសើរឡើងបាន។ តាមការលើកឡើងនេះ អង្គជំនុំជម្រះបានពិភាក្សារកដំណោះស្រាយសមហេតុផល ប្រសិនបើស្ថានភាពរបស់គាត់ហាក់ដូចជាមិនអាចប្រសើរឡើង ហើយការពិភាក្សានេះ អាចនឹងក្លាយជាដំណោះស្រាយពាក់ព័ន្ធ ប្រសិនបើស្ថានភាពរបស់លោកស្រីមិនរីកចំរើនទេ។ ក្រុមចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះបានរកឃើញថា ខណៈដែលមានមូលដ្ឋានផ្លូវច្បាប់ដើម្បីបន្តការឃុំខ្លួនលោកស្រី **អៀង ធីរិទ្ធ** មូលដ្ឋាននោះគឺស្ថិតក្នុងចំណុះយ៉ាងធំធេងលើភាពដែលអាចទៅបាន ដែលលោកស្រីអាចនឹងក្លាយទៅជាមានសម្បទាសមរម្យក្នុងការជំនុំជម្រះនាពេលអនាគត។ តែប្រសិនបើវាទំនងជាមិនអាចកើតឡើងបានវិញនោះ ទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិគាំទ្រនូវការសន្មតទុកជាមុនមួយ ដោយអនុគ្រោះនៃសុចរិតភាព និងសេរីភាពជាបុគ្គលវិញ។[88]

ម្យ៉ាងវិញទៀត អង្គជំនុំជម្រះនៃតុលាការកំពូលបានកត់សម្គាល់ថា "វិធានការដែលមិនសូវរឹតត្បិត" (ឧទាហរណ៍ៈ ការដោះលែងបណ្តោះអាសន្ន) គឺគួរតែធ្វើ ប្រសិនបើគោលបំណងនៃការបន្តការឃុំឃាំងអាចនឹងធ្វើដោយយន្តការត្រឹមត្រូវតាមគោលបំណងនៃវិធានការមួយនេះ។[89] អង្គជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា "ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មិនអនុញ្ញាតឲ្យមានការឃុំខ្លួនដោយបង្ខំនៅក្នុងមន្ទីរពេទ្យ ឬទីកន្លែងប្រហាក់ប្រហែលសំរាប់អំឡុងពេលនៃការត្រួតពិនិត្យតាមផ្លូវតុលាការនោះទេ"។[90] ការលើកឡើងដូចនេះ ប្រសិនបើគោលបំណងគឺមិនមានការប៉ុនប៉ងក្នុងការអង្កេតថែទាំសុខភាពរបស់លោកស្រី **អៀង ធីរិទ្ធ** ហើយស្ថានភាពផ្លូវចិត្តឲ្យបានកាន់តែជិតដល់តាមដែលអាចធ្វើទៅបាន ទម្រង់នៃការដោះលែងអាចនឹងក្លាយជាជម្រើសមួយទៀត។[91]

---

88 ICCPR, Articles 9(1) and 14(2); Cambodian Code of Criminal Procedure, Article 305; Internal Rule 82(1).

89 SUPREME COURT DECISION, par. 45. 22.

90 Ibid, par. 46. 22.

91 When the Supreme Court Chamber ordered the Trial Chamber to carry out the appropriate medical care and assessment of IengThirith's fitness to stand trial, the Chamber specifically cautioned that "the Trial Chamber must be vigilant [during this

មេធាវីការពារក្ដីរបស់លោកស្រី **អៀង ធីរិទ្ធ** បានតវ៉ាថា សំរាប់ការដោះលែងភ្លាមៗកាលពីថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ពីព្រោះតែលោកស្រីត្រូវបានឃុំឃាំងមិនស្របច្បាប់តាំងពីក្នុងរយៈពេលមុនដំណាក់កាលសវនាការមកម្ល៉េះ។ [92] យោងទៅតាមកតិកាសញ្ញាស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ICCPR ក៏ដូចជាច្បាប់បង្កើត **អ.វ.ត.ក** លោកស្រី **អៀង ធីរិទ្ធ** មានសិទ្ធិទទួលការជំនុំជម្រះ "ដោយមិនមានការពន្យារ"។[93] វិធានផ្ទៃក្នុង ២១(៤) ថ្លែងថា "ការសម្រេចសេចក្ដីលើការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ ត្រូវធ្វើការជំនុំជម្រះនៅក្នុងរយៈពេលមួយសមស្រប"។ ជាក់ស្ដែងប្រសិនបើមានលទ្ធភាពត្រឹមតែតិចតួច ឬមិនអាចទៅរួចទាល់តែសោះ ដែលលោកស្រី **អៀង ធីរិទ្ធ** អាចនឹងជាសះស្បើយព្រមទាំងអាចមានសម្បទាពេញលេញក្នុងការជំនុំជម្រះ វាមិនមានន័យអ្វីនឹងបន្តធ្វើការឃុំខ្លួនលោកស្រីបន្តទៀតនោះទេ។

ព្រោះតែមានការប្រកាសនូវប្រភេទនៃឧក្រិដ្ឋកម្មមួយចំនួន លោកស្រី **អៀង ធីរិទ្ធ** អាចនឹងមានគ្រោះថ្នាក់បង្កដោយប្រជាជនដែលប្រាថ្នាចង់បានយុត្តិធម៌ដោយដៃពួកគេផ្ទាល់ ប្រសិនបើគាត់ត្រូវបានដោះលែងនោះ។ ស្រដៀងគ្នានេះដែរ សមាជិកជាតិ និងអន្តរជាតិជាច្រើន អាចនឹងមិនពេញចិត្តប្រសិនបើលោកស្រី **អៀង ធីរិទ្ធ** ត្រូវបានដោះលែងឲ្យដើរហើរមានសេរីភាពក្នុងដំណាក់កាលនេះ។ តាមការលើកឡើងនេះ វាអាចនឹងមានគ្រោះថ្នាក់មួយនៃការធ្វើបាតុកម្មសាធារណៈជាទ្រង់ទ្រាយធំ ឬអាចមានបញ្ហាជាច្រើនផ្សេងទៀតនៃបញ្ហាសន្តិសុខ និងបទបញ្ជាសាធារណៈ ប្រសិនបើលោកស្រី **អៀង ធីរិទ្ធ** ត្រូវបានដោះលែង។ បន្ថែមពីនេះទៀត ការដោះលែង អាចនឹងមានការព្រួយបារម្ភអំពីផលប៉ះទង្គិចគ្នារវាងលោកស្រីលើបញ្ហាសង្គម។ ឧទាហរណ៍ពីលោក **ឆាង យុគ** ដែលជាសាក្សីម្នាក់ក្នុងសំណុំរឿង០០២ បានប្រកាសថា លោកស្រី **អៀង ធីរិទ្ធ** បានព្យាយាមគម្រាមកំហែងប្អូនស្រីរបស់លោក ក្នុងការដាក់គំនាបលើរូបលោកឲ្យឈប់ធ្វើការងារស៊ើបអង្កេតដូចដែលគាត់បានធ្វើកន្លងមក។[94]

អង្គជំនុំជម្រះ បានជជែកវែកញែកអំពីបញ្ហាថាតើពួកគេមានការទទួលខុសត្រូវក្នុងការការពារជនជាប់ចោទពីការវាយប្រហារទាំងឡាយទាំងពួងនោះឬយ៉ាងណា បើការការពារមិនត្រូវបានធ្វើការស្នើសុំឡើងនោះ។ ក្រុមចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះបានរកឃើញថា ព្រោះតែមេធាវីការពារក្ដីលោកស្រី **អៀង ធីរិទ្ធ** មិនបានធ្វើការស្នើសុំឲ្យបញ្ជូនជនជាប់ចោទទៅព្យាបាលនៅមន្ទីរពេទ្យ និងស្នើសុំដាក់ក្រោមការធានាសន្តិសុខពីសំណាក់រាជរដ្ឋាភិបាលកម្ពុជាឡើយ។[95] អង្គជំនុំជម្រះនៃតុលាការកំពូលបានរកឃើញថា តុលាការត្រូវតែមានការព្រួយបារម្ភពីសុវត្ថិភាពរបស់ជនជាប់ចោទ ហើយ

process] that any continued detention would not be for an unreasonably long period of time, in breach of internationally recognized human rights." (Ibid, par. 30. 17.)

92 IengThirith Defense. "Request for immediate release of madameIengThirith" (21 January 2011). E21.

93 ICCPR, Article 14 (3)(c); ECCC Law, Article 35new (c).

94 Trial Chamber. Transcript of Trial Proceedings (1 February 2012). E1/37.1. lines 18-23. 110.

95 TRIAL CHAMBER DECISION, par. 75. 26.

ហេតុដូចនេះ អង្គជំនុំជម្រះត្រូវតែធ្វើការវាយតម្លៃលើកម្រិតនៃការគំរាមកំហែងផ្សេងៗប្រឆាំងនឹងជនជាប់ចោទ ដែលអាចនឹងកើតមានមុនពេលការធ្វើសេចក្តីសម្រេចចាត់វិធានការនៃបញ្ហាសន្តិសុខនាពេលអនាគត។[96]

## ផ្នែកទី ៦ៈ ការពិនិត្យឡើងវិញនូវសមត្ថភាពរបស់លោកស្រី អៀង ធីរិទ្ធ កាលពីខែសីហា ឆ្នាំ២០១២

### ក. របកគំហើញពីអ្នកជំនាញការ

អង្គជំនុំជម្រះ បានស្តាប់នូវការវិភាគថ្មីមួយទៀតពីសម្បទាក្នុងការជំនុំជម្រះរបស់លោកស្រី **អៀង ធីរិទ្ធ** កាលពីថ្ងៃទី៣០ ដល់៣១ ខែសីហា ឆ្នាំ២០១២[97] និងបានចេញសេចក្តីសម្រេចរបស់ខ្លួនកាលពីថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២។[98] វាមានលទ្ធផលសំខាន់ៗបីដែលចេញពីលទ្ធផលនៃសវនាការពីថ្ងៃនេះគឺៈ (១) គឺថាលោកស្រី **អៀង ធីរិទ្ធ** ត្រូវបានរកឃើញថាមានសម្បទាពេញលេញក្នុងការជំនុំជម្រះ និងត្រូវបានកោះហៅឲ្យចូលរួមក្នុងសវនាការ។ (២) គឺថាលោកស្រីត្រូវបានរកឃើញថាមិនមានសម្បទាពេញលេញ ក៏ប៉ុន្តែបានបន្តឲ្យមានការឃុំខ្លួនដោយសំអាងលើហេតុផលសុវត្ថិភាព (ទាំងខ្លួនលោកស្រីផ្ទាល់ និងសុវត្ថិភាពសំរាប់សាធារណជនផងដែរ) និង (៣) គឺថាលោកស្រីត្រូវបានរកឃើញថាមិនមានសម្បទាសមរម្យ និងត្រូវបានដោះលែងដោយមានលក្ខខណ្ឌ ឬមិនមានលក្ខខណ្ឌ។ នៅក្នុងជម្រើសពីរចុងក្រោយ អង្គជំនុំជម្រះអាចជ្រើសយកការអនុញ្ញាតចេញដីកាបណ្តោះអាសន្នប្រឆាំងលើរូបលោកស្រី ឬក៏ដកចេញនូវដីកាបណ្តោះអាសន្ននេះ។

អង្គជំនុំជម្រះបានពិនិត្យសាឡើងវិញ នូវរបាយការណ៍ជាលាយលក្ខណ៍អក្សរពីអ្នកជំនាញការវេជ្ជសាស្ត្រទាំងបួនរូប និងបានស្តាប់ការផ្តល់សក្ខីកម្មពីអ្នកជំនាញការទាំងបួននៅក្នុងតុលាការផងដែរៈ សាក្សីជំនាញទាំងបីដែលបានផ្តល់សក្ខីកម្មកាលពីពេលមុនទាក់ទងនឹងសមត្ថភាពផ្លូវចិត្តរបស់លោកស្រី **អៀង ធីរិទ្ធ** និងសាក្សីជំនាញថ្មីមួយរូបទៀត គឺលោកស្រីវេជ្ជបណ្ឌិត **ចក់ ធីតា**។ អ្នកជំនាញទាំងពីរក្រុម បានធ្វើបទបង្ហាញនូវភាពមិនស៊ីគ្នានៃរបកគំហើញយ៉ាងដាច់ស្រឡះ។ លោកវេជ្ជបណ្ឌិត **ចន ខាំបល** លោកវេជ្ជបណ្ឌិត **ស៊ីណា ហ្វីហ្សេល** និងលោកវេជ្ជបណ្ឌិត **ហួត លីណា** បានរកឃើញថា "មិនមានភស្តុតាងណាមួយបញ្ជាក់ពីភាពអាចប្រសើរឡើងនៃស្ថានភាពជំងឺរបស់លោកស្រី **អៀង ធីរិទ្ធ** ទេ។ ជាការពិត យើងមានអារម្មណ៍ថាស្ថានភាពនោះ កាន់តែយ៉ាប់យ៉ឺនឡើងៗ"។ ចំណុចជាក់លាក់ដែលអ្នកជំនាញបានរកឃើញថា លោកស្រី **អៀង ធីរិទ្ធ** មិនអាចរំលឹកនូវប្រធានបទមួយចំនួនសូម្បីតែមួយ ឬពីរនាទីក្រោយការសួរនាំរបស់ពួកគេ ហើយពួកគាត់កត់សម្គាល់ថា ទាំង

---

96 SUPREME COURT DECISION, par. 47. 23.

97 Trial Chamber. "Scheduling of reassessment and hearing on IENG Thirith fitness to stand trial" (22 June 2012). E138/7/13. p. 2.

98 Trial Chamber. "Decision on Reassessment of Accused IENG Thirith's Fitness to Stand Trial Following Supreme Court Chamber Decision of 13 December 2011" (13 September 2012). E138/1/10 [hereinafter, **TRIAL CHAMBER REASSESSMENT DECISION**].

នេះគឺមិនមែនជាសញ្ញានៃអាយុកាលចាស់ជរារបស់គាត់ទេ ក៏ប៉ុន្តែវាជាការចុះខ្សោយការចងចាំ។ ម៉្យាងវិញទៀត លោកវេជ្ជបណ្ឌិតទាំងបីមិនជឿថាមានវិធីព្យាបាលណាមួយអាចធ្វើទៅបានទេ ដើម្បីព្យាបាលនូវស្ថានភាពដែលលោកស្រី **អៀង ធីរិទ្ធ** កំពុងតែមានសព្វថ្ងៃនេះ។

លោកស្រីវេជ្ជបណ្ឌិត **ចក់ ធីតា** បានរកឃើញថា លោកស្រី **អៀង ធីរិទ្ធ** មានសមត្ថភាពផ្លូវចិត្តពេញលេញ ទោះបីជាគាត់ត្រូវបានសួរនាំនូវវិធីផុយស្រួយយ៉ាងណាក៏ដោយ។ លោកស្រីវេជ្ជបណ្ឌិតបានរកឃើញថា ស្ថានភាពរបស់លោកស្រី **អៀង ធីរិទ្ធ** អាចស្ថិតក្នុងដំណាក់កាលមួយដែលគេហៅថា "ដំណាក់កាលដំបូងនៃជំងឺវង្វេងវង្វាន់ ប៉ុន្តែមិនទាន់ដល់ដំណាក់កាលយ៉ាប់យ៉ឺនពេកនៅឡើយទេ។ លោកស្រី វេជ្ជបណ្ឌិត **ចក់ ធីតា** បានយកមូលដ្ឋាននៃការរកឃើញរបស់លោកស្រីពីលទ្ធផលនៃឧបករណ៍ធ្វើតេស្ត MMSE[99] ដែលបានប្រើដោយវេជ្ជបណ្ឌិតទាំងអស់នៅគ្រប់ដំណាក់កាលនីមួយៗនៃការធ្វើតេស្តលើសមត្ថភាពយល់ដឹងរបស់ជនជាប់ចោទ **អៀង ធីរិទ្ធ**។ វេជ្ជបណ្ឌិត **ចក់ ធីតា** បានរកឃើញថា ជនជាប់ចោទបានទទួលពិន្ទុ២៤នៃពិន្ទុសរុប៣០ ដែលការឲ្យពិន្ទុនេះគឺខ្ពស់ដាច់គ្នាស្រឡះពីការឲ្យពិន្ទុរបស់ក្រុមគ្រូពេទ្យក្រុមមួយទៀតដែលបានចុះក្នុងបញ្ជីពិនិត្យតាមដាន ហើយកំណត់ត្រាបានចុះថាលោកស្រី **អៀង ធីរិទ្ធ** មិនដែលបានទទួលពិន្ទុលើសពី១៨នៃពិន្ទុសរុប៣០ឡើយ។ លោកស្រីវេជ្ជបណ្ឌិត **ចក់ ធីតា** មានអារម្មណ៍ថា គាត់មានសមត្ថភាពចម្រាញ់យកនូវការឆ្លើយតបល្អប្រសើរដែលមានភាពត្រឹមត្រូវជាងតាមរយៈការបង្ហាញ នូវសមត្ថភាពផ្លូវចិត្តរបស់លោកស្រី **អៀង ធីរិទ្ធ** ព្រោះតែទាំងលោកស្រីវេជ្ជបណ្ឌិតផ្ទាល់ខ្លួន ហើយខណៈជនជាប់ចោទ **អៀង ធីរិទ្ធ** ជាជនជាតិកម្ពុជា និងមានភេទដូចគ្នា ដូច្នេះ ទាំងនេះអាចនាំឲ្យមានភាពល្អប្រសើរជាងក្នុងការទំនាក់ទំនងជាមួយជនជាប់ចោទ។

វេជ្ជបណ្ឌិតបីរូបពីក្រុមមួយទៀត បានតវ៉ាថា លោកស្រីវេជ្ជបណ្ឌិត **ចក់ ធីតា** មិនបានធ្វើការត្រួតពិនិត្យការធ្វើតេស្តតាមមធ្យោបាយត្រឹមត្រូវនោះទេ ក្រៅពីបានសួរតែសំណួរមួយចំនួនម្តងដូច្នេះ ម្តងដូច្នោះ និងបានធ្វើឲ្យសំណួរទាំងនោះមានភាពងាយស្រួលជាងសំណួរដើមដែលបានកំណត់។ ការធ្វើបែបនេះ គឺមានន័យថាធ្វើឲ្យវាមិនអាចទៅរួចនៅក្នុងការប្រៀបធៀបនៃការត្រួតពិនិត្យនីមួយៗដែលវេជ្ជបណ្ឌិត **ចក់ ធីតា** បានត្រួតពិនិត្យកន្លងមក និងបានធ្វើឲ្យការរកឃើញរបស់លោកស្រីវេជ្ជបណ្ឌិតខ្លួនឯង មានភាពយល់ឃើញខុសគ្នាពីការរកឃើញពីសំណាក់អ្នកជំនាញក្រុមមួយទៀត។

លោកស្រី **ចក់ ធីតា** បានសារភាពថា វិធីសាស្ត្រដែលលោកស្រីបានប្រើប្រាស់ក្នុងការពិនិត្យតាមដានតាមរយៈឧបករណ៍ធ្វើតេស្តនោះ គឺដោយសារតែវាបានទទួលរងឥទ្ធិពលពីអង្គហេតុដែលថា លោកស្រី **អៀង ធីរិទ្ធ** គឺជាជនសង្ស័យក្នុងសំណុំរឿង០០២។ លោកស្រីវេជ្ជបណ្ឌិតមានអារម្មណ៍ថា ជនជាប់ចោទ **អៀង ធីរិទ្ធ** នឹងមិនអាចធ្វើកិច្ចសហប្រតិបត្តិការជាមួយពួកគេ (អ្នកជំនាញការ) បានទេ ប្រសិនបើលោកស្រី **អៀង ធីរិទ្ធ** បានដឹងថាទង្វើនោះគឺជាការពិនិត្យស្ទាបស្ទង់នូវការចងចាំរបស់

[99] Mini-Mental State Exam

គាត់ ក៏ដូចជាសម្បទារបស់គាត់ក្នុងការជំនុំជម្រះ ដូច្នេះហើយបានជាលោកស្រីវេជ្ជបណ្ឌិតត្រូវតែប្រុងប្រយ័ត្នក្នុងការសួរនាំលើជនសង្ស័យរូបនេះ។ អ្នកជំនាញការទាំងបីក្នុងក្រុមមួយទៀត បានរ៉ាយរ៉ាប់ថា ពួកគាត់ជឿជាក់ថាវាមានការលំបាកណាស់ក្នុងការធ្វើពុត ឬបន្លំជាមួយនឹងជំងឺវិកលចរិកៈ នៅពេលដែលមនុស្សធ្វើដូចនេះ ពួកគេជាទូទៅនៅតែមិនផ្លាស់ប្ដូរនូវអ្វីដែលពួកគេធ្វើ ហើយមិនអាចមានការចងចាំឡើយ ចំណែកឯលោកស្រី **អៀង ធីរិទ្ធ** គឺមានការផ្លាស់ប្ដូរញឹកញាប់បំផុត ម្ដងយ៉ាងដូច្នេះម្ដងយ៉ាងដូច្នោះ។ បន្ដមកទៀត អ្នកជំនាញទាំងបីរូបបានថ្លែងថា វាជាការលំបាកមួយក្នុងការបន្លំធ្វើជាព្រងើយកន្ដើយដោយបដិសេធមិនព្រមធ្វើអនាម័យផ្ទាល់ខ្លួន ជាពិសេស ការនោមជុះដោយមិនដឹងខ្លួនជាដើម។

## ខ. ការជជែកតវ៉ារវាងភាគី

ផ្អែកលើរបកគំហើញទាំងនេះ ភាគីសហព្រះរាជអាជ្ញា ភាគីការពារដើមបណ្ដឹងរដ្ឋប្បវេណី និងភាគីក្រុមការពារក្ដីរបស់លោកស្រី **អៀង ធីរិទ្ធ** បានផ្ដល់នូវមតិយោបល់របស់គេរៀងៗខ្លួនលើបញ្ហានេះ។

ភាគីសហព្រះរាជអាជ្ញា បានយល់ស្របចំពោះការដែលតុលាការបានតែងតាំងឲ្យមានអ្នកជំនាញការវេជ្ជសាស្ត្រដែលលោកស្រី **អៀង ធីរិទ្ធ** មិនមានសម្បទាពេញលេញក្នុងការធ្វើការជំនុំជម្រះ ហើយមិនទំនងទេដែលលោកស្រី **អៀង ធីរិទ្ធ** នឹងមានសម្បទាពេញលេញវិញបានក្នុងការជំនុំជម្រះនាពេលអនាគតដ៏ខ្លីខាងមុខនេះ។ ប្រការនេះ ភាគីសហព្រះរាជអាជ្ញាបានស្នើថាការដោះលែងដោយមានលក្ខខណ្ឌដែលអាចការពារលោកស្រីជាជនជាប់ចោទផង ការពារនូវសុវត្ថិភាពរបស់អ្នកដទៃផ្សេងទៀត បូករួមនឹងការផ្ដល់លទ្ធភាពនៃអង្កេតតាមដានស្ថានភាពវេជ្ជសាស្ត្ររបស់លោកស្រីផងដែរ ថែមទាំងអនុញ្ញាតឲ្យមានអានុភាពខាងផ្នែកគតិយុត្តិប្រសិនបើលោកស្រី **អៀង ធីរិទ្ធ** ប៉ុនប៉ងជ្រៀតជ្រែកជាមួយនឹងការងាររបស់តុលាការ។[100]

ដោយឡែក ភាគីដើមបណ្ដឹងរដ្ឋប្បវេណីវិញ បានគាំទ្រដល់ការរកឃើញរបស់វេជ្ជបណ្ឌិត **ចក់ ធីតា** និងបានតវ៉ាថា សកម្មភាព ឬទង្វើដែលបានធ្វើដោយវេជ្ជបណ្ឌិត **ចក់ ធីតា** តាមរយៈការធ្វើតេស្ដពិនិត្យតាមដានរបស់ខ្លួន គឺមានលក្ខណៈសមរម្យជាងក្នុងបរិបទនៃប្រជាជនកម្ពុជា។ មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានស្នើសុំឲ្យមានការតែងតាំងវេជ្ជបណ្ឌិតជាស្ត្រីភេទច្រើនថែមទៀតដើម្បីធ្វើការដេញរកហេតុផលនៃស្ថានភាពរបស់លោកស្រី **អៀង ធីរិទ្ធ**។

ក្រុមមេធាវីការពារក្ដីរបស់លោកស្រី **អៀង ធីរិទ្ធ** បានតវ៉ាថា អ្នកជំនាញការទាំងបួនក្រុមបានធ្វើតេស្ដសាកល្បងរួចរាល់ហើយលើជនជាប់ចោទរូបនេះ និងបានរកឃើញថា លោកស្រី **អៀង ធីរិទ្ធ**

100 The OCP's six conditions are: 1) that IengThirith reside at a specific, recorded address; 2) that authorities conduct a weekly safety check of her home; 3) that she surrender her passport and ID card; 4) that she not contact any other Accused except her husband, IengSary; 5) that she not contact any witness, expert or victim who may be heard in Court; 6) that she submit to a regular medical examination by a court-appointed doctor every 6 months. The OCP suggested that if she breached these conditions, a more restrictive measure, such as house arrest, might be considered.

មិនអាចនឹងមានសម្បទាពេញលេញក្នុងការជំនុំជម្រះទេ ហេតុដូច្នេះហើយ តុលាការគួរតែដោះលែងជនជាប់ចោទ **អៀង ធីរិទ្ធ** ដោយគ្មានលក្ខខណ្ឌអ្វីទាំងអស់។ ភាគីការពារក្តីបានធ្វើការជំទាស់នូវការស្នើសុំពីភាគីព្រះរាជអាជ្ញានៃការដោះលែងមានលក្ខខណ្ឌ និងបានតវ៉ាថាការឃុំឃាំងគឺគ្រាន់តែជាមធ្យោបាយសមគួរ ក្នុងការធានាឲ្យមានការចូលរួមរបស់ចុងចោទម្នាក់ក្នុងសវនាការតែប៉ុណ្ណោះ។ ភាគីការពារក្តីបានតវ៉ាថា ចាប់តាំងពីការចោទប្រកាន់ទាំងឡាយត្រូវបានផ្អាក ឯការចូលរួមក្នុងសវនាការ គឺលែងមានការពាក់ព័ន្ធទៀតហើយ មានន័យថាលោកស្រី **អៀង ធីរិទ្ធ** គួរតែត្រូវបានដោះលែងដោយមិនមានហេតុផល។

### គ. កង្វល់ផ្លូវច្បាប់ និងកង្វល់នៃការអនុវត្ត

ដូចដែលតុលាការបានពិភាក្សារួចមកហើយ មានភាពប្លែកពីគ្នានៃដំណោះស្រាយគតិយុត្តិ និងហេតុផលនៃការអនុវត្តថាតើហេតុអ្វីវាអាចបង្ខាំងជនជាប់ចោទក្នុងមន្ទីរឃុំឃាំងបាន រួមបញ្ចូលទាំងការធានាឲ្យការមានវត្តមានរបស់លោកស្រីជាជនជាប់ចោទក្នុងសវនាការ បូករួមទាំងការការពារលោកស្រីពីកំហឹងរបស់សាធារណជន ក៏ដូចជាការពារសាធារណជនពីការជ្រៀតជ្រែករបស់លោកស្រី។ ទោះជាយ៉ាងនេះក្តី ក៏មានភាពខុសគ្នាមួយនៃហេតុផលផ្លូវច្បាប់ និងហេតុផលនៃការអនុវត្តដើម្បីបន្តរក្សាទុកជនជាប់ចោទ **អៀង ធីរិទ្ធ** នៅក្នុងមន្ទីរឃុំឃាំង។ ចំណុចសំខាន់គឺថា មិនមានមធ្យោបាយស្រួលបួលក្នុងការថែទាំបញ្ហាផ្លូវចិត្តណាមួយនៅប្រទេសកម្ពុជាទេ ដែលប្រការនេះលោកស្រី **អៀង ធីរិទ្ធ** អាចទាំងត្រូវបានបន្តការឃុំឃាំងផង និងបានទទួលការថែទាំសុខភាពផង។ ម៉្យាងវិញទៀត សំណួរមួយអាចនឹងសួរថាតើតុលាការអាចនឹងមានអំណាចក្នុងការបន្តឃុំខ្លួនលោកស្រី **អៀង ធីរិទ្ធ** មិនកំណត់ពេលដោយមិនមានសវនាការមួយត្រូវបានធ្វើឡើងឬយ៉ាងណា ឯការស្វែងរកពិរុទ្ធភាព មានបញ្ហាស្រដៀងគ្នាជាមួយនឹងការបញ្ជាឲ្យមានការព្យាបាលដោយខានមិនបាននៅពេលដែលវាលែងមានការពាក់ព័ន្ធសំរាប់ការដឹកនាំដំណើរការយុត្តិធម៌មួយទៅហើយនោះ។ បន្ថែមពីនេះទៀត ប្រសិនបើតុលាការបានរកឃើញថា លោកស្រី **អៀង ធីរិទ្ធ** មានសម្បទាពេញលេញក្នុងការជំនុំជម្រះ ហើយធ្វើការកោះហៅឲ្យចូលខ្លួនក្នុងសវនាការ តុលាការទំនងជាប្រឈមមុខផ្នែកហិរញ្ញវត្ថុ និងផលលំបាកផ្នែករៀបចំទូទៅនៃដំណើរការសវនាការសំណុំរឿងរបស់លោកស្រី **អៀង ធីរិទ្ធ**។[101]

### ឃ. សេចក្តីសម្រេចថ្មីបំផុតលើបញ្ហានេះ

កាលពីថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២ អង្គជំនុំជម្រះបានចេញសេចក្តីវិនិច្ឆ័យមួយស្តីពីសម្បទាពេញលេញក្នុងការជំនុំជម្រះលើករណីរបស់លោកស្រី **អៀង ធីរិទ្ធ**។[102] អង្គជំនុំជម្រះបានរក

---

[101] Cambodian judges were not paid October 2011 to March 2012, and all Cambodian staff of the Court remained unpaid January to March of 2012. This is not the first time in the Court's history that this has happened. (Phnom Penh Post. "Cash Crunch at Khmer Rouge Tribunal." 18 January 2012. <http://www.phnompenhpost.com/index.php/2012011954035/National-news/cash-crunch-at-kr-tribunal.html>, accessed 23 July 2012.)

[102] TRIAL CHAMBER REASSESSMENT DECISION.

ឃើញថា លោកស្រី **អៀង ធីរិទ្ធ** មិនមានសម្បទាពេញលេញក្នុងការជំនុំជម្រះទេ ដោយបានបញ្ជាក់នូវការពន្យារពេលមិនកំណត់ព្រំដែននៃដំណើរការសវនាការប្រឆាំងលើលោកស្រី **អៀង ធីរិទ្ធ** និងបានដោះលែងលោកស្រីជាមួយនឹងការកំណត់លក្ខខណ្ឌមួយចំនួន។[103] អង្គជំនុំជម្រះបានគាំទ្រនូវការសន្មតទុកជាមុននូវការអនុគ្រោះដល់ការមានសេរីភាព ជាពិសេសក្នុងករណីដែលបានកើតឡើងក្នុងដូចសំណុំរឿងមួយនេះ ដោយការឃុំឃាំងនឹងលែងមានសារៈសំខាន់ទៀតហើយ ដើម្បីធានាថាជនជាប់ចោទនឹងត្រូវបង្ហាញខ្លួនក្នុងបន្ទប់តុលាការ។

លោកស្រី **អៀង ធីរិទ្ធ** ត្រូវបានដោះលែងភ្លាមៗពីមន្ទីរឃុំឃាំង **អ.វ.ត.ក** ប៉ុន្តែអនុលោមទៅតាមវិធានផ្ទៃក្នុង៣៥[104] ត្រូវតែទប់ស្កាត់នូវការជ្រៀតជ្រែកជាមួយនឹងការគ្រប់គ្រងផ្នែកយុត្តិធម៌ ជាពិសេស ការជ្រៀតជ្រែកពីសាក្សី អ្នកជំនាញការ និងជនរងគ្រោះនៅចំពោះមុខ **អ.វ.ត.ក** ក៏ដូចជាជនជាប់ចោទផ្ទាល់ ថែមទាំងពីសំណាក់ប្តីរបស់លោកស្រីផងដែរ គឺជនជាប់ចោទ **អៀង សារី**។[105] លោកស្រី ក៏បានស្នើសុំបន្តទៀតនូវការទប់ស្កាត់ការធ្វើទំនាក់ទំនងជាមួយនឹងសារព័ត៌មាន ដែលជាប់ទាក់ទងនឹងការិយាល័យ **អ.វ.ត.ក** នៃចំណាត់ការនៃការផ្លាស់ប្តូរអាសយដ្ឋាន។ អង្គជំនុំជម្រះបានជំទាស់នូវការកម្រិតលក្ខខណ្ឌផ្សេងៗទៀតពីភាគីព្រះរាជអាជ្ញា។

ទោះជាយ៉ាងណា អង្គជំនុំជម្រះបានសង្កត់ធ្ងន់ថា "បទចោទប្រឆាំងនឹងជនជាប់ចោទ **អៀង ធីរិទ្ធ** គឺពុំត្រូវបានលុបចោលនោះទេ ហើយក៏មិនអាចបង្កើតបាននូវសេចក្តីសម្រេចចិត្តពីពិរុទ្ធភាព ឬភាពស្អាតស្អំ (គ្មានទោស) នៃជនជាប់ចោទបានដែរ"។[106] ម្យ៉ាងវិញទៀត អង្គជំនុំជម្រះបានគ្រោងនឹងធ្វើការប្រឹក្សាជាមួយអ្នកជំនាញការផ្នែកវេជ្ជសាស្រ្តប្រចាំឆ្នាំ ចាប់ផ្តើមពីខែមីនា ឆ្នាំ២០១៣ ទៅហើយនិងបន្តរហូតទាល់តែ **អ.វ.ត.ក** នៅបន្តដំណើរការរបស់ខ្លួនក្នុងកិច្ចពិភាក្សា ប្រសិនបើមានពិធីសាស្រ្តថ្មីក្នុងការព្យាបាលត្រូវបានយល់ព្រមឲ្យធ្វើដែលវិធីសាស្រ្តនោះ អាចនឹងធ្វើឲ្យស្ថានភាពរបស់លោកស្រី **អៀង ធីរិទ្ធ** មានភាពប្រសើរឡើង។ តាមការលើកឡើងមកនេះ វាអាចទៅរួចដែលសវនាការលើលោកស្រី **អៀង ធីរិទ្ធ** អាចនឹងចាប់ផ្តើមធ្វើជាថ្មីម្តងទៀតនៅកាលបរិច្ឆេទខាងមុខ។

## ផ្នែកទី ៧៖ បណ្តឹងសាទុក្ខចុងក្រោយបំផុត

ភាគីសហព្រះរាជអាជ្ញា បានរៀបចំបណ្តឹងសាទុក្ខភ្លាមៗចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងបានតវ៉ាថា អង្គជំនុំជម្រះបានប្រើពាក្យច្បាប់ខុសដោយបានចេញបញ្ជាឲ្យមានការដោះលែងជនជាប់ចោទដោយគ្មានលក្ខខណ្ឌ និងបានស្នើថា អង្គជំនុំជម្រះគួរតែដាក់បន្ថែមនូវស្ថានភាពតឹងតែងផ្សេងៗទៀតមុនធ្វើការដោះលែងជនជាប់ចោទ។[107] ចំណុចជាក់លាក់ដែលភាគី

[103] Ibid, 19.
[104] Internal Rule 35, particularly (d)(e).
[105] Per Internal Rule 35.
[106] TRIAL CHAMBER REASSESSMENT DECISION, par. 40, 18.
[107] Co-Prosecutors. "Immediate appeal against decision on reassessment of accused IengThirith's fitness to stand trial following the Supreme Court Chamber decision of 13 December 2011" (14 September 2012). E138/1/10/1/1.

សហព្រះរាជអាជ្ញាចង់ឲ្យអង្គជំនុំជម្រះបន្តបង្គាប់ឲ្យធ្វើតាម និងដាក់ឲ្យមានការព្យាបាលផ្នែកវេជ្ជសាស្ត្រដល់លោកស្រី **អៀង ធីរិទ្ធ**។ ភាគីការពារក្តី បានឆ្លើយតបចំពោះការធ្វើបណ្តឹងសាទុក្ខកាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២ ហើយបានស្នើទៅកាន់អង្គជំនុំជម្រះតុលាការកំពូលឲ្យធ្វើការបដិសេធចោលលនូវបណ្តឹងសាទុក្ខមួយនេះ និងដកចេញទាំងអស់នូវលក្ខខណ្ឌបង្គាប់បញ្ជាទាំងឡាយ ដែលបច្ចុប្បន្នបានភ្ជាប់ជាមួយនឹងការដោះលែងដល់ជនជាប់ចោទ **អៀង ធីរិទ្ធ**។[108] ភាគីការពារក្តីបានបន្តស្នើសុំឲ្យមានសវនាការផ្ទាល់មាត់ (Oral hearing) លើបញ្ហានេះ។ អង្គជំនុំជម្រះតុលាការកំពូលនឹងស្តាប់នូវការជជែកតវ៉ាមួយចំនួនក្នុងបណ្តឹងឧទ្ធរណ៍មួយនេះ ហើយក៏នឹង"ពិភាក្សាផងដែរស្តីពីអាណាព្យាបាលរបស់ជនជាប់ចោទមួយរូប គឺអ្នកស្រី **អៀង វិជិដា**" នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១២។[109]

## ផ្នែកទី ៨៖ បញ្ហាផ្លូវច្បាប់ផ្សេងៗទៀត៖ ដំណោះស្រាយជាមួយនឹងភាពខ្វះខាតនៃសំឡេងគាំទ្រភាគច្រើន

ដូចដែលបានធ្វើការកត់សម្គាល់ក្នុងរបាយការណ៍មួយនេះ អង្គចៅក្រមនៃអង្គជំនុំជម្រះ ត្រូវបានបំបែកតាំងពីខាងដើមលើបញ្ហាថាតើលោកស្រី **អៀង ធីរិទ្ធ** អាចនឹងអាចជាសះស្បើយ និងអាចមានសម្បទាពេញលេញក្នុងការជំនុំជម្រះឬយ៉ាងណា ហើយថាតើ អង្គជំនុំជម្រះអាចបង្គាប់ឲ្យមានការព្យាបាលផ្នែកវេជ្ជសាស្ត្រដល់លោកស្រី ដើម្បីជាជំនួយជួយឲ្យគាត់បានជាសះស្បើយឡើងវិញបាន។

ក្រុមចៅក្រមជាតិបីរូបយល់ថា វាមានឱកាសមួយដែលលោកស្រី **អៀង ធីរិទ្ធ** អាចនឹងមានស្ថានភាពល្អប្រសើរឡើងបាន ហើយក៏ចង់ឲ្យមានការព្យាបាលផ្នែកវេជ្ជសាស្ត្រដល់រូបគាត់។ ក្រុមចៅក្រមអន្តរជាតិពីររូបផ្សេងទៀតបានគិតថា មិនមានមូលដ្ឋានណាមួយដែលគួរតែគិតថាស្ថានភាពជំងឺរបស់លោកស្រី **អៀង ធីរិទ្ធ** អាចនឹងជាសះស្បើយបាន ហើយវាក៏មិនមានមូលដ្ឋានណាមួយដើម្បីក្នុងការបង្គាប់ឲ្យមានការព្យាបាលផ្នែកវេជ្ជសាស្ត្រដល់ជនជាប់ចោទរូបនេះដែរ។

អង្គជំនុំជម្រះសាលាដំបូង មិនមានភាពច្បាស់លាស់ពីរបៀបក្នុងការដោះស្រាយបញ្ហានេះទេ ដោយសារកង្វះខាតនៃសំឡេងភាគច្រើន។[110] អង្គជំនុំជម្រះ បានសម្រេចជាយថាហេតុថា ជាមួយនឹងច្បាប់ដែលមានទំនាស់គ្នា"ការបង្កើតភាពតឹងរឹងនៃលក្ខន្តិកៈព្រហ្មទណ្ឌតម្រូវឲ្យការបកស្រាយត្រូវផ្តល់ប្រយោជន៍ដល់ជនជាប់ចោទ"។[111] ហេតុដូច្នេះហើយ អង្គជំនុំជម្រះត្រូវតែស្វែងរកនូចំណុច

---

[108] IengThirith Defense. "Defense response to Co-Prosecutors' immediate appeal against decision on reassessment of accused IengThirith's fitness to stand trial following the Supreme Court Chamber decision of 13 December 2011 and Co-Prosecutors' supplementary submissions" (8 October 2012). E138/1/10/1/5/3.

[109] Trial Chamber. "Order Scheduling Appeal Hearing" (5 November 2012). E138/1/10/1/5/5.

[110] ECCC LAW, Article 14(1)(a) requires the affirmative vote of at least four judges at the Trial stage, and six at the Supreme Court level. However, there are no provisions in the ECCC Law or Agreement stipulating how to deal with a lack of supermajority. Furthermore, this is an unusual provision for an international court, so there are not international precedents. (TRIAL CHAMBER DECISION, par. 79. 28.)

[111] TRIAL CHAMBER DECISION, par. 80. 29.

អនុគ្រោះនៃការបកស្រាយដែលផ្តល់ភាពអនុគ្រោះបំផុតដល់ជនជាប់ចោទ ហើយត្រូវតែមានការសន្មតទុកជាមុនថាគ្មានទោស ហើយមិនមានសំឡេងគ្រប់គ្រាន់នៅក្នុងការទាមទារសិទ្ធិសេរីភាពបុគ្គល។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូង បានបង្គាប់ឲ្យធ្វើការដោះលែងលោកស្រី **អៀង ធីរិទ្ធ** ភ្លាមៗ និងគ្មានលក្ខខណ្ឌ។ អង្គជំនុំជម្រះតុលាការកំពូល បានបដិសេធជាបន្តបន្ទាប់នូវផ្នែកនៃសេចក្តីសម្រេចខ្លះៗពីអង្គជំនុំជម្រះសាលាដំបូង ព្រោះដូចដែលក្រុមចៅក្រមជាតិនៃអង្គជំនុំជម្រះបានលើកឡើង គឺថាពួកគាត់យល់ថាវាអាចនឹងទៅរួចដែលលោកស្រី **អៀង ធីរិទ្ធ** អាចនឹងជាសះស្បើយ ហើយមានសម្បទាពេញលេញក្នុងការជំនុំជម្រះ។ ហេតុដូច្នេះហើយ វិធានការសព្វបែបយ៉ាងគួរតែត្រូវខ្នះខ្នែងសាកល្បងធ្វើ។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះនៃតុលាការកំពូល បានរារាំងនូវការដោះស្រាយបញ្ហាស្តីពីការទទួលយកនីតិវិធីពីអង្គជំនុំជម្រះសាលាដំបូង ក្នុងការជ្រើសយកមធ្យោបាយនៃការជ្រើសយកសំឡេងភាគច្រើនក្នុងការចេញសេចក្តីសម្រេច។

* AIJI is a collaborative project between the East-West Center, in Honolulu, and the War Crimes Studies Center, University of California, Berkeley. Since 2003, the two Centers have been collaborating on projects relating to the establishment of justice initiatives and capacity-building programs in the human rights sector in South-East Asia. The Program is funded by the Open Society Foundation, the Foreign Commonwealth Office of the British Embassy in Phnom Penh, and the Embassy of Switzerland in Bangkok.

This issue of KRT TRIAL MONITOR was authored by Mary Kristerie A. Baleva, Faith Suzzette Delos Reyes, Samantha B. Lee, Ramu Nachiappan, and Penelope Van Tuyl, as part of AIJI's KRT Trial Monitoring and Community Outreach Program. KRT TRIAL MONITOR reports on Case 002 are available at <www.krtmonitor.org>, and at the websites of the East-West Center and the War Crimes Studies Center.

**Unless specified otherwise,**

- the documents cited in this report pertain to *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* before the ECCC;
- the quotes are based on the personal notes of the trial monitors during the proceedings;
- the figures in the *Public Attendance* section of the report are only approximations; and
- photos are courtesy of the ECCC.

**Glossary of Terms**

| | |
|---|---|
| Case 001 | *The Case of Kaing Guek Eav alias "Duch"*(Case No. 001/18-07-2007-ECCC) |
| Case 002 | *The Case of Nuon Chea, Ieng Sary, Ieng Thirith and Khieu Samphan* (Case No. 002/19-09-2007-ECCC) |
| CPC | Code of Criminal Procedure of the Kingdom of Cambodia (2007) |
| CPK | Communist Party of Kampuchea |
| CPLCL | Civil Party Lead Co-Lawyer |
| DK | Democratic Kampuchea |
| ECCC | Extraordinary Chambers in the Courts of Cambodia (also referred to as the Khmer Rouge Tribunal or "KRT") |
| ECCC Law | Law on the Establishment of the ECCC, as amended (2004) |
| ERN | Evidence Reference Number (the page number of each piece of documentary evidence in the Case File) |
| FUNK | National United Front of Kampuchea |
| GRUNK | Royal Government of National Union of Kampuchea |
| ICC | International Criminal Court |
| ICCPR | International Covenant on Civil and Political Rights |
| ICTR | International Criminal Tribunal for Rwanda |
| ICTY | International Criminal Tribunal for the former Yugoslavia |
| IR | Internal Rules of the ECCC Rev. 8 (2011) |
| KR | Khmer Rouge |
| OCIJ | Office of the Co-Investigating Judges |
| OCP | Office of the Co-Prosecutors of the ECCC |
| RAK | Revolutionary Army of Kampuchea |
| VSS | Victims Support Section |
| WESU | Witness and Expert Support Unit |

EAST-WEST CENTER

AIJI TRIAL MONITORING

WCSC
WAR CRIMES STUDIES CENTER
UNIVERSITY OF CALIFORNIA, BERKELEY